Reçu le 28-12-51

INDOCHINE FRANÇAISE RÉGIE DU DÉPÔT LÉGAL

# មិត្តសាលាបាលី

ទស្សនាវដ្ដីផ្សាយពុទ្ធសាសនា និង អក្សរសាស្ត្រខ្មែរ

ចេញរាល់ខែ



ឆ្នាំទី២ មិថុនា - កក្កដា លេខ៦-៧

ព. ស. ២៤៩៤ — គ. ស. ១៩៥១

ទស្សនាវដ្ដីអនុមាសផ្សាយព្រះពុទ្ធសាសនានឹងអក្សរសាស្ត្រខ្មែរ

បណ្ណាធិការ ឈឹម-ក្រសេម

សំណាក់ការលេខ ៣៩ អា., វីថីឧកញ៉ាពេជ្រ ក្រុងភ្នំពេញ

## បញ្ជីរឿង


| បញ្ជីរឿង | | ទំព័រ |
|---|---|---|
| វិបារណកថា | | ២០១ |
| ព្រះពុទ្ធសាសនាគឺអ្វី? (តមកនឹងចប់) | ភិក្ខុប៉ាង-ខាត់ | ២០៥ |
| សាសនាក្នុងប្រទេសកម្ពុជា | ឈឹម-ក្រសេម | ២១៦ |
| អគ្គញ្ញសូត្រ (តមកនឹងចប់) | ញ៉ុង-សឿង | ២២២ |
| លោកវិបារ | ភ័យ-ប៊ុក | ២២៥ |
| សង្គហធម៌ | ព្រះពោធិភម ជា-ទន់ | ២៣១ |
| ប្រវត្តិសម្ដេចព្រះសុគន្ធាធិបតី ប៉ាន | ប៊ូ-ប៉ូ | ២៤១ |
| ការកសាងខ្លួនដើម្បីទទួលសេចក្ដីសុខ | ហេង-យ៉ាន់ | ២៤៤ |
| សកុន្តលា | ហេង-យ៉ាន់ | ២៥៦ |
| បញ្ចតន្ត្រៈ (តមក) សេចក្ដីប្រែរបស់ | ភិក្ខុប៉ាង-ខាត់ | ២៧១ |


---

ដំឡៃជាវប្រចាំឆ្នាំ ១០០ រៀល

---

អ្នកអានទាំងឡាយ! សូមអញ្ជើញចុះឈ្មោះជាវ!

នឹងបបួលញាតិមិត្តជួយជាវ!

ជីវិតទស្សនាវដ្ដីសូមផ្ញើលើលោកអ្នក ។

1951 -16,71

# វិចារណកថា

បើកបររថយន្ត តែងតួហ៊ឺហា ចេះក្រេបរសស្រុក ចូលចិត្តល្បែង ប្រៀងកំ ជាដើម ដែលពួកច្រើនគេទុកជាការឃោសនាទូវការទាន់សម័យ ។ ពិតមែនហើយតែជីវិតរបស់យើង ទាំងផ្លូវកាយ ទាំងផ្លូវចិត្ត ត្រូវការសេចក្តីកំសាន្តខ្លះ ទើបរីករាយស្រស់ស្រាយ តែយើងពុំមែនរស់នៅដើម្បីសេចក្តីក្អើតក្អើនសប្បាយតែម្យ៉ាងប៉ុណ្ណោះទេ បើដូច្នោះតើ ការទាន់សម័យសមដូចសេចក្តីយល់ខាងលើនេះឬ?

ពាក្យថាទាន់សម័យតោងបរិយាយ ដល់យឺតសម័យឬលឿនសម័យផង អ្នកដើរមិនទាន់ពេលវេលាគួរទុកជាអ្នកយឺតសម័យ អ្នកកន្លងពេលវេលាហួសហេតុ ជាអ្នកលឿនសម័យ ឯអ្នកទាន់សម័យនោះ គឺអ្នកដែលដើរតាមកាលវេលា ។

អ្នកប្រាថ្នាកាមទាំងឡាយ ជាអ្នកប្រកបដោយលោភៈ ធ្វើខ្លួនឲ្យជាប់ជំពាក់ក្នុងអារម្មណ៍ដកខ្លួនទៅណាពុំរួច រមែងមិនចេះឆ្អែត មិនចេះគ្រប់គ្រាន់ក្នុងការបរិភោគវត្ថុកាម តែងកន្ទុះរាធ្វេធ្វាឥតស្រាក បណ្តោយឲ្យកាលវេលាកន្លងហួសទៅជានិច្ច កំពុងត្រេកត្រអាលពុំទាន់អស់ចិត្តផង ស្រាប់តែអស់កាលទៅ ដូច្នេះអ្នកប្រាថ្នាកាម មានសេចក្តីពេញចិត្តក្នុងការតាក់តែងអាត្មា ល្បែងប្រៀងកំជាដើមជាអ្នកទ្យឡាមិនទាន់ពេលវេលា ជាអ្នកយឺតសម័យ ពុំមែនជាអ្នកទាន់សម័យ ដូចគេធ្លាប់យល់មកនោះទេ ។

ចំណែកឯអ្នកធ្វើការអ្វី និយាយអ្វី គិតអ្វី ដោយកម្លាំងទោសៈដុត តែងតែជ្រុលមុនការងារ សំឡាប់ទាំងប្រយោជន៍អ្នកដទៃ ទាំងប្រយោជន៍ខ្លួន ឲ្យវិនាសបង់មុននឹងបានសម្រេចផលដោយពិតប្រាកដ ញ៉ាំងកិច្ចការនានា ដែលប្រារព្ធនឹងធ្វើឲ្យឆេះខ្ទេចខ្ទីអស់ ដោយយល់ថាខ្លួនត្រូវ ខ្លួនគ្រាន់បើជាងគេ នេះឈ្មោះថា ធ្វើអ្វីដែលពុំទាន់មកដល់ ដែលបំរុងនឹងមានមកជាប្រយោជន៍អ្នកដទៃ នឹងជាប្រយោជន៍ខ្លួនឲ្យដល់ឆាប់ហើយវិនាសបង់ទៅ គឺថាជាអ្នកលឿនសម័យ ។

ឯអ្នកខ្លះទៀតវិលវល់ងងឹតដូចខ្វាក់ ពុំដឹងទិសតំបន់ឯណា ពុំដឹងជាទៅពីណា ទៅទីណា ឆ្ពោះទៅកាន់កន្លែងណា វង្វេងតែម្នាក់ឯងកណ្ដាលអធ្វា ទៅមុខក៏មិនដឹង ថយក្រោយក៏មិនដឹង ព្រះអាទិត្យរះឬលិច គេនឹងជាអ្វីដល់មនុស្សខ្វាក់ អ្នកក្រាស់ដោយមោហៈនោះ។ ជនបំពួកនេះ ទុកជាអ្នក មិនស្គាល់សម័យ ពេលគេដេកខ្លួនដើរ ពេលគេដើរខ្លួនដេក ។

ដូច្នេះ អ្នកដែលប្រកបដោយលោភៈ ទោសៈ មោហៈ ជាអ្នកមិនទាន់សម័យ ជាអ្នករកប្រយោជន៍បច្ចុប្បន្ន នឹងប្រយោជន៍បរលោកមិនឃើញ ។

ព្រោះហេតុនោះ បើមានមិត្តភក្ដិណា អ្នករាប់អានណា មកបញ្ចូលចិត្ត ឬមកណែនាំប្រាប់ថា អ្នកដែលនឹងធ្វើខ្លួនឲ្យជាអ្នកទាន់សម័យបាន នោះ តោងចេះតែងខ្លួនឲ្យហ៊ឺហា ចេះផឹកស្រាមេរ័យ ចេះស្រើបស្រាល

ក្នុងល្បែងប្រៀងកំ នឹងគ្រឿងកាមទាំងឡាយ, យើងគួរកំណត់ក្នុងចិត្តថា អ្នកនោះជាបាបមិត្ត ជាមិត្តជំរុញយើងឲ្យធ្លាក់ទៅកាន់ទីទាប ឲ្យបាននូវសេចក្តីវិនាសគ្រប់ប្រការ អ្នកទាំងនោះហើយជាអ្នកយឺតសម័យ ឡេឡាក្រោយគេ រកផ្លូវសួគ៌ផ្លូវនិព្វានពុំឃើញ រវល់តែជាប់ជំពាក់ក្រាញជាប់ក្នុងសង្សារវដ្តដែលរកទីបំផុតគ្មាន ។

ចំណែកខាងព្រះពុទ្ធសាសនាវិញ លោកប្រដៅមិនឲ្យជាប់ជំពាក់ក្នុងអារម្មណ៍ដែលកន្លងហួសទៅហើយ និងក្នុងអារម្មណ៍ដែលពុំទាន់មានមកដល់ អារម្មណ៍ដែលកន្លងទៅហើយ អារម្មណ៍នោះ យើងបានលះបង់ចោលស្រឡះហើយ អារម្មណ៍ណាដែលមិនទាន់មកដល់ អារម្មណ៍នោះយើងក៏ពុំទាន់បានដល់ តើយើងនឹងទៅប្រាថ្នាចំពោះអារម្មណ៍ ដែលគ្មាននោះធ្វើអ្វី? បានប្រយោជន៍អ្វីនឹងជញ្ជឹងគិត និងអាលោះអាល័យ និងចង្អៀតចង្អល់ចិត្តចំពោះអារម្មណ៍ ដែលកន្លងទៅហើយនោះ? បច្ចុប្បន្នពុំមែនជាផលនៃអតីតឬ? បានប្រយោជន៍អ្វីនឹងការក្ដួតខ្លួនឯងដោយតុបតែងមនោភាពយ៉ាងស្រស់ស្រាយចំពោះអនាគត ដើម្បីកែសភាពលំបាកគោកយ៉ាកនៃបច្ចុប្បន្ន? បច្ចុប្បន្នពុំមែនជាបច្ច័យកសាងអនាគតឬ?

ព្រោះហេតុនោះ ទើបព្រះបរមគ្រូជាម្ចាស់ ទ្រង់ត្រាស់ប្រដៅឲ្យគិតចំពោះធម៌ជាបច្ចុប្បន្នដោយសេចក្តីមិនស្រើបស្រាល ដោយតាំងចិត្តនឹងដុតបំផ្លាញកិលេស ឲ្យឆេះរលាយខ្ចាត់ខ្ចាយចេញពីខន្ធសន្តានឲ្យបាន

ក្នុងថ្ងៃនេះ ព្រោះឥតមាននរណាអាចកំណត់អនាគតរបស់ខ្លួន ថាមានត្រឹមណាបានទេ ។ ព្រះអង្គដាស់តឿនឲ្យមានសតិគ្រប់កាលដើម្បីពិចារណានូវកាយ វេទនា ចិត្ត ធម៌ដែលកំពុងប្រព្រឹត្តទៅនៅចំពោះមុខ មិនឲ្យកន្លងនូវសេចក្តីពិចារណាបាន ការមានសតិតាំងមាំជានិច្ចបែបនេះ ជាហេតុនាំឲ្យប្រុងប្រយ័ត្ន មិនមានសេចក្តីធ្វេសប្រហែសចំពោះពេលវេលា ឈ្មោះថាបានបំពេញកិច្ចការទាន់ពេលវេលាជាដរាប ។

ដឹងថាថ្ងៃដែលត្រូវទៅ ដឹងថាទៅដើម្បីអ្វី ដឹងថាកំពុងដើរទៅ តើមិនឈ្មោះថាបំពេញគ្រប់ៗខណៈនៃជីវិតឬ? រស់នៅដោយដឹងខ្លួនជានិច្ច ដោយភ្ញាក់រលឹកជានិច្ច តើមិនមែនជាការរស់នៅក្នុងជីវិតដ៏ពេញបរិបូណ៌ឬអ្វី? នេះហើយជាកិច្ចនៃពុទ្ធសាសនិកជនគប្បីប្រតិបត្តិ រហូតដល់បានបំពេញករណីយកិច្ចគ្រប់គ្រាន់ជាបំផុត គឺ ថាជាអ្នកទាន់សម័យពិតប្រាកដ ។ ការទាន់សម័យស្ថិតនៅត្រង់ការមិនបណ្តោយ ឲ្យកាលវេលាទំពាស៊ីជីវិតទៅឯងៗ ដោយមិនបានគ្រប់គ្រងដោយល្អ ដើម្បីដុសខាត់សន្តានឲ្យបានស្អាតបរិសុទ្ធ ត្រង់ការឆ្ពោះត្រង់តាមផ្លូវទៅទាន់ទីបំណង ដោយមិនរវើរវាយចិត្ត មិនឈ្ងក់ក្នុងការគយគន់ថ្នាក់ថ្នមបុប្ផានានា ដែលដុះដេរដាសនៅមាត់ផ្លូវ មិនវិលវល់ក្នុងការស្រមាក់ស្រមៃដប់បុប្ផាដែលកន្លងហួសមកហើយ ។

ម្នាលអានន្ទ! អ្នកណាមួយ ទោះជាភិក្ខុក្តី ជាភិក្ខុនីក្តី ជាឧបាសកក្តី ជាឧបាសិកាក្តី ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីគោរពក្រែង ប្រព្រឹត្តតាមធម៌, អ្នកនោះទើបឈ្មោះថា ធ្វើសក្ការៈ គោរព រាប់អាន និងបូជា ចំពោះតថាគត ដោយការបូជាដ៏ប្រសើរបំផុត ។

មហាបរិនិព្វានសូត្រ មហា. ទីឃ.

## ព្រះពុទ្ធសាសនា គឺអ្វី?

(តមក និង ចប់)

ថ្ងៃមួយ ជាលើកទី ៣ ព្រះអង្គប្រថាប់លើរថ មានឆន្នអាមាត្យជាសារថី ស្តេចចេញទៅប្រពាតឧទ្យានម្តងទៀត ទ្រង់ទតព្រះនេត្រឃើញមនុស្សស្លាប់ មានមនុស្ស ៤ នាក់សែង មានញាតិសន្តានស្រីប្រុសដើរហែហមមុខក្រោយកំពុងរំសាយសក់ ស្រែកទ្រហោយំ ទង្គិះខ្សឹកខ្សួល បំរះនទៀលតាមមគ្គមាគ៌ា ទើបត្រាស់សួរឆន្នអាមាត្យថា: មនុស្សអ្វីនុះហ្ន៎? ” ។ ឆន្នអាមាត្យក្រាបទូលថា “សូមទ្រង់មេត្តាប្រោស មនុស្សនេះហៅមនុស្សស្លាប់ ស្លាប់មកពីកើតៗ ហើយចាស់ឈឺស្លាប់ មិនថាក្មេងចាស់ មានក្រ មានបុណ្យ ឥតបុណ្យអ្វីទេ តែមានកើតហើយ ស្លាប់គ្រប់គ្នាទាំងអស់” ។ ព្រះអង្គបានជ្រាបសំវេគធម៌នេះ ពីកាលស្តេច

ទតឃើញ មនុស្សចាស់ឈឺមកផង ទ្រង់សន្ទប់ព្រះស្មារតីផ្អែកទៅលើ ទ្រពង់រថ ភ្ញាក់ព្រះស្មារតីឡើងហើយ ទ្រង់បែរព្រះនេត្របាញ់ត្រង់ទៅ រកមនុស្សស្លាប់នោះ ដកអស្សាសបស្សាសៈវែងៗ មានបន្ទូលមុខគួរឲ្យសំវេគថា "ឱលោកនេះអើយចិត្តអ័ករឹងម្ល៉េះហ្ន៎ បើរូបនេះមានសត្រូវគឺ ជរា ព្យាធិ មរណៈ បៀតបៀនញាំញីឲ្យបានទុក្ខវេទនាខ្លាំងម្ល៉េះ? លោកនេះមានចិត្តដូចឈើ បើទុកជាឃើញឈើផងគ្នា ដុះសន្ទឹក របកសំបក នៅតែដើមជ្រឹង កំផុតបេះដូងសំវេគតក់ស្លុតទឹងគ្នាទេ ឱមុខគួរសំវេគណាស់ហ្ន៎!!!"

នែឆន្ន! អ្នកចូរបររថចូលទៅកាន់រាជវាំងឲ្យឆាប់ៗទៅ ព្រោះចិត្តខ្ញុំឆ្ងាកបែរចេញពីសេចក្ដីត្រេកអរក្នុងឧទ្យានភូមិហើយ ទ្រង់បន្ទូលឲ្យបររថត្រឡប់យ៉ាងនេះគ្រប់ចាំង ៣ ដង ៗ តមក, ទ្រង់តែងមានព្រះដំរិះជាប់ក្នុងព្រះទ័យ ជានិច្ចថា: "ប្រាជ្ញប្រាសាទរាជវាំងជាទីរុងរឿងស្រណុកស្រណាននេះ ទឹងមានប្រយោជន៍អ្វី បើគេមិនអាចការពារខ្លួនឲ្យរួចពីជរាព្យាធិមរណៈបាន, ការកើតជាមនុស្សនេះ លំបាកច្រើនយ៉ាងណាស់ ប្រហែលជាមិនមានផ្លូវ មិនមានវិធីទឹងគេចឲ្យរួចពីសេចក្ដីទុក្ខនេះទេឬអ្វីហ្ន៎?" ៗ

ថ្ងៃមួយ ជាលើកទី ៤ ព្រះអង្គប្រថាប់លើរថ ចេញទៅជាមួយឆន្នអាមាត្យជាសារថីទៀត ទ្រង់ទតព្រះនេត្រឃើញបព្វជិតស្លៀកពាក់

បរិមណ្ឌលមានបុកពាសុភាពស្រគត់ស្រគំ ស្ងប់ជាសុខក្សេមក្សាន្ត ។ ព្រះអង្គត្រាស់ស្ដួរឆន្ទអាមាត្យៗ ក្រាបទូលតាមដំណើរសព្វគ្រប់នាំឲ្យទ្រង់ជ្រះថ្លាសប្បាយរីករាយព្រះទ័យ ហើយបង្គាប់សារថីឲ្យបររថទៅប្រពាតខុទ្យានភូមិអស់ទិវសកាលសម័យ ។ បព្វជិតនេះជាវង់កសិណកើតជាបដិភាគនិមិត្តជាប់នៅក្នុងព្រះទ័យជានិច្ច ហើយទ្រង់ពិចារណាតែក្នុងព្រះទ័យថា "បព្វជិតនេះ មានឧកាសល្អណាស់ សំរាប់ធ្វើការ ព្រមទាំងធ្វើអ្វីៗ ឲ្យសមទៅតាមចិត្តដោយសេរី បព្វជិតនេះជាវិជ្ជាបានមួយសម្រាប់គន់គិត ធ្វើទិទស្សន៍ រកវិធីយកឈ្នះសេចក្ដីទុក្ខលោកនេះបាន" ។ តមកថ្ងៃមួយ មានរាជបុរសម្នាក់ចូលទៅក្រាបទូលក្នុងពេលដែលស្ដេចប្រពាតខុទ្យានថា "ព្រះរាជបុត្រប្រសូតហើយ" ពេលនោះទ្រង់ភ្ញាក់ព្រះឧស្ពមានបន្ទូលខ្លាំងៗ ថា "ឧរាហូចាប់អញហើយ! រាហូចាប់អញហើយ!" ។ ព្រះបន្ទូលនេះទៅជារាហុលៈ បានជាព្រះនាមព្រះរាជបុត្រ ។

តមក ព្រះអង្គមានព្រះទ័យញាប់ញ័ររន្ធត់ជានិច្ច មិនដែលបានស្ងប់ក្សេមក្សាន្តសោះ ព្រោះវង់កសិណគឺអារម្មណ៍មនុស្សចាស់ឈឺស្លាប់មកប្រាកដដល់មនោទ្វារ ឃើញលោកសន្និវាសទាំងមូល សុទ្ធតែក្ដើងទុក្ខ គឺចាស់-ឈឺ-ស្លាប់ កព្រោលកេលរែកស្ទន់ស្ទោអន្ទះសា ហើយទៅស្វែងរកសេចក្ដីសុខតែក្នុងក្ដើងទុក្ខ មិនមានបញ្ញាចក្ខុរែកមើលផ្លូវថ្មី

យកឈ្នះទុក្ខឲ្យបានសេចក្ដីសុខពិតៗ ដែលសេចក្ដីសុខគឺព្រះនិព្វាន
ដល់ម្នាក់ឡើយ ទ្រង់ព្រះចិន្ដាណាស់ទៅ ឃើញហេតុដល់ប្រាសាទ
ពដ៏ពាំងក៏ត្រូវភ្លើងឆេះសន្ធោសន្ធៅដូចគ្នាដែរ ទ្រង់ឃើញតែប្រកមួយ
ជាប្រកយកឈ្នះសេចក្ដីទុក្ខហើយបានសុខពិតគឺមហាភិនិស្ក្រម ៗ ព្រះ
អង្គមានវ័យនៅកំពុងពេញពាល ព្រះជន្ម ២៩ ព្រះវស្សា ព្រះកេស
កំពុងខ្មៅស្រិល ព្រះវរបិតាព្រះអគ្គមហេសី ព្រះរាជបុត្រ ព្រះរាជបរិពារ
កំពុងសោកសៅ បំរះនទៀល ទឹកនេត្រស្រក់សស្រាក់ពេញភក្ត្រា
ទ្រង់ជាប់ព្រះទ័យចេញចាកលោក ចេញចាកស្វែងរកកុសល ដើម្បី
យកឈ្នះសេចក្ដីទុក្ខ ៗ ព្រះអង្គយកភេទជាបព្វជិត ប្រដាប់ត្រៃចីវរ
មិនមានទោសដល់ការនៅព្រៃ ស្វះស្វែងរកមេសាស្ដាមានកេរ្ដិ៍ឈ្មោះ
ល្បីល្បាញ ហើយទ្រង់ក៏បានជួបអាឡារកាឡាមគោត្រនិងឧទករាមបុត្រ
ជាឫសីមានបណ្ដាជនគោរពរាប់អានច្រើនក្នុងសម័យនោះ ទ្រង់សិក្សាហេតុ
ដល់ជ្រាបនូវលទ្ធិសម័យឫសីទាំងពីរយ៉ាងច្បាស់លាស់ ហើយទ្រង់
ឃើញថាមិនមែនជាផ្លូវនាំឲ្យយកឈ្នះទុក្ខបានពិតប្រាកដ ទើបទ្រង់លា
ចាកចេញទៅ ៗ ព្រះអង្គប្រថាប់នៅតាមទំនើងព្រះអង្គ ត្រាច់ចុះឡើង
នៅតែក្នុងឧរុវេលប្រទេស សេនានិគម ដែនមគធ រំពឹងគិតធ្វើពិសោធ
ស្ទាបស្ទង់មើលរកផ្លូវ ជួនកាលល្បងធ្វើទុក្ករកិរិយា យ៉ាងតឹងរឹងទីបំផុត
ដែលឥតមានមនុស្សជាតិធ្វើតាមបាន ដើម្បីឲ្យដឹងថាផ្លូវនោះៗ គេយក

ឈ្នះទុក្ខបានឬមិនបាន ដូចសោយអាហារតិច ឬមិនសោយសោះ ប្រថាប់នៅពេញមួយថ្ងៃៗ មិនក្រោកសោះ ធ្វើអានាបានស្សតិកម្មដ្ឋានទាល់តែរាងកាយស្គាំងស្គមមានតែស្បែកដណ្តប់ឆ្អឹងដូច្នេះជាដើម ព្រះវរកាយដែលបរិសុទ្ធផូរផង់នោះក្លាយទៅជាក្រោងឆ្អឹងរគីមរគាមដូចបង្កង់ដៃវណង ផ្ទះចាស់ គឺក្រោងឆ្អឹងដើរបាន តែព្រះទ័យបរិសុទ្ធ សូម្បីក្មេងគង្វាលគោបៀតបៀនបន្ទោបង់ឧច្ចារបស្សាវៈដាក់ ឬយកឈើចាក់ប្រកាណ៌លេង ក៏ទ្រង់តាំងព្រះទ័យឧបេក្ខាព្រងើយកន្តើយ ។ ទីបំផុត ព្រះអង្គពិចារណាតាមការពិសោធន៍ល្បងមើលទាំងប៉ុន្មានឃើញថា មិនមែនជាផ្លូវយកឈ្នះសេចក្តីទុក្ខបានទេ តែបើទុកជាទ្រង់ឃើញដូច្នេះ ក៏ទ្រង់មិនរួញរាថយព្រះទ័យទ្រង់នៅតែមានសង្ឃឹមជឿថា គង់មានផ្លូវដទៃផ្សេងទៀតដែលអាចរំលត់សេចក្តីទុក្ខបាន ។ ព្រះអង្គពិចារណាឃើញថា មុននឹងឲ្យចិត្តស្ងប់ត្រូវឲ្យរាងកាយស្ងប់សិន ព្រោះកាយនិងចិត្តនេះ ជាធម្មជាតិទាក់ទងគ្នាទៅវិញទៅមក កាយជាផ្ទះជ្រកនៅនៃចិត្ត បើកាយលំបាកទូរន់ទូរគ្រាំគ្រា ចិត្តក៏ក្រវល់ក្រវាយនៅស្ងប់មិនបានទេ ព្រោះមកពីចិត្តជាធម្មជាតតែងគ្របដណ្តប់ទៅលើកាយ ហេតុនោះ បើចង់ឲ្យចិត្តស្ងប់ក្សេមក្សាន្តមិនក្រវល់ក្រវាយ ត្រូវតែបំប៉នកាយដោយអាហារ បរិហាររាងកាយដែលជាទីជ្រកនៅនៃចិត្តឲ្យរឹងប៉ឹងមាំមួនមុនសិន ។ ការធ្វើរាងកាយឲ្យលំបាកជាអត្តកិលមថានុយោគ ដោយគិតឃើញថាជាផ្លូវរួចពីសេចក្តីទុក្ខនេះ មិនមែន

ជាគន្លងធម៌ទេ បានជាពួកតាបសឬសីទាំងឡាយដែលប្រព្រឹត្តអត្តកិលម-
ថានុយោគមិនបានសម្រេចប្រយោជន៍ បានតែនាំឲ្យរាងកាយនឿយហត់
ឥតអំពើ មកតែពីយល់ខុសនេះឯង ៗ តមក ព្រះអង្គត្រឡប់សោយ
អាហារដូចប្រក្រតីដើមវិញ ៗ កាលទ្រង់សោយអាហារហើយ ព្រះ
វរកាយក៏មាំមួនបរិសុទ្ធផូរផង់ឡើងវិញ ព្រះទ័យស្ងប់មិនក្រវល់ក្រវាយ ៗ
ទ្រង់រឭកដល់ការស្ងប់ក្សាន្តព្រះទ័យ ដែលទ្រង់បានក្រោមដើមព្រីងក្នុង
ពិធីវប្បមង្គលព្រះបាទសិរីសុទ្ធោទនព្រះវររាជបិតា ហើយទ្រង់យកមកជា
អារម្មណ៍កម្មដ្ឋាន ធ្វើព្រះទ័យឲ្យស្ងប់ត្រជាក់មានបីតិបាមោជ្ជ អាចគន់
គិតរកប្រស្នាសេចក្ដីសុខពិត ៗ ទីបំផុត ទ្រង់គត់ព្រះភ្នែនពែនព្រះបាទ
ក្រោមពោធិព្រឹក្ស តាំងសច្ចាបណិធានប្ដេជ្ញាព្រះទ័យដាច់ខាតថា “បើ
រកប្រស្នាដោះព្រះអង្គពីសេចក្ដីទុក្ខមិនរួចទេ ទ្រង់មិនក្រោកចាកបល្ល័ង្កទេ
ស្បែក ឈាម ឆ្អឹង សាច់ សរសៃ រីងស្ងួតក្រៀមក្រញង់ចុះ” តមក ទ្រង់
ធ្វើសង្គ្រាមតស៊ូកិលេសមារពេញមួយរាត្រី យាមជាបឋម បានបុព្វេ-
និវាសានុស្សតិញ្ញាណ ជាវិជ្ជាទីមួយ, មជ្ឈិមយាម បានចុតូបបាតញ្ញាណ
ជាវិជ្ជាទីពីរ, មជ្ឈិមយាម ពេលបច្ចូសសម័យ បានអាសវក្ខយញ្ញាណជា
វិជ្ជាទី ៣ ទើបបានជ្រាបថា សង្គ្រាមធំ ដែលទ្រង់មិនដែលឈ្នះជាអនេក-
ជាតិ ទ្រង់ឈ្នះហើយលែងត្រឡប់ចាញ់វិញ ទ្រង់យកឈ្នះសេចក្ដីទុក្ខ
បានហើយ អវិជ្ជាបាត់ទៅហើយ វិជ្ជាកើតឡើងហើយ ធម៌ទ្រង់បានត្រាស់

ដឹងហើយ នៅថ្ងៃ ១៥ កើតខែពិសាខមុន ព. ស. ៤៥ឆ្នាំ នៅក្បែរស្ទឹងនេរញ្ជរា នាពុទ្ធគយាសព្វថ្ងៃ ។ ព្រះសិទ្ធត្ថកុមារដែលទល់ទុក្ខ ទំរកប្រស្នា យកឈ្នះទុក្ខមកយូរយារហើយនេះឯង បាននេមិត្តកនាមថា សម្មាសម្ពុទ្ធ ។

ព្រះសម្មាសម្ពុទ្ធនេះ ព្រះអង្គបើកលោកដោយព្រះអង្គឯង ហើយទ្រង់មានប្រាថ្នានឹងឲ្យសត្វលោកបើកលោកដូចព្រះអង្គផង ។ ពាក្យថា ព្រះអង្គបើកលោកនេះគឺភពមនុស្ស ភពទេវតា នឹងភពព្រហ្មដែលនៅងងឹតគេមើលមិនយល់មិនស្គាល់ជាអ្វីនោះ ព្រះអង្គបានឃើញច្បាស់ឥតសល់កំបាំង ដូចជាវត្ថុដែលគេគ្របលាក់ទុក ហើយគេបើកបង្ហាញ ឬតុំនោះ ដូចនៅក្នុងគេហដ្ឋានមួយដ៏ងងឹតឈឹង អ្នកនៅក្នុងគេហដ្ឋាននោះមើលអ្វីមិនឃើញសោះ ព្រោះងងឹតខ្លាំងណាស់បេះតែការ រាវទៅៗទៅប្រទះដែកកើង គូសកើតឡើង ពន្លឺដេញងងឹតចេញបាត់ទៅ មើលឃើញវត្ថុនៅជុំវិញខ្លួនច្បាស់ថា នេះខ្មៅ នេះស ខ្ពស់ទាបជាដើម ។ ព្រះអង្គក៏ភ្ញាក់ព្រឺតដែរ បានគេថ្វាយព្រះនាមថា ពុទ្ធោ ព្រោះកាលមុនពីកាលបានត្រាស់ដឹង គឺកាលទ្រង់មិនទាន់បានត្រាស់ដឹងធម៌ នៅសភាពជាបុថុជ្ជនដូចយើងនៅឡើយ ទ្រង់ធ្ងល់ណាស់ ទ្រង់បេះតែរិះរកផ្លូវថា ផ្លូវដូចម្តេចហ្ន៎ នាំឲ្យរួចពីទុក្ខលោក យកឈ្នះទុក្ខលោកនេះបាន បានជាទ្រង់មានបន្ទូលរឿយៗ ក្នុងពេលដែលស្វែងរកធម៌ថា : "តថាគតស្វែះស្វែងរកគឺកុសលសន្តិវរបទ គឺអ្វីជាកុសលជាផ្លូវស្ងប់ប្រសើរ" ដល់ពេល

ដែលបានទ្រង់ត្រាស់ដឹងនៅក្រោមពោធិព្រឹក្ស ទើបទ្រង់ភ្ញាក់ព្រះអង្គ ព្រើតដោយពន្លឺប្រាជ្ញាដូចពុទ្ធតម្រាស់ថា "អវិជ្ជាបាត់ទៅ ញាណកើតឡើង" ពន្លឺកើតឡើងមើលឃើញលោកនេះច្បាស់លាស់តាមយថាភូត-ទស្សនញ្ញាណ ទ្រង់ប្រៀបព្រះអង្គថាដូចកូនមាន់ដែលចោះសំបកពងចេញមកមើលឃើញពន្លឺលោកមុនគេ ក្នុងបណ្ដាកូនមាន់ទាំងឡាយ ៗ កូនមាន់ដែលចោះសំបកពងមុនគេ មើលឃើញពិតថា "នេះមនុស្ស នេះដើមឈើ នេះផែនដី នេះព្រះអាទិត្យដួលចុះជាដើមយ៉ាងណា ឯព្រះសម្មាសម្ពុទ្ធ ពេលអវិជ្ជាបាត់ទៅ ញាណកើតឡើងក្នុងពេលបច្ចូសសម័យ ទ្រង់ឃើញលោក បើកលោក ចាក់ធ្លុះដោយយថាភូតទស្សនញ្ញាណយ៉ាងនោះ ៗ ទ្រង់ឃើញពិតថា "សំខារទាំងអស់ជាអនិច្ចំ ជាទុក្ខំ ជាអនត្តា" សាមញ្ញលក្ខណៈនេះ ត្រូវតាមរូបមន្តដែលចេញចាកការនិទស្សន៍ អ្នកវិទ្យាសាស្ត្រខាងរូបនិយមដែលពោលក៏ប់រងថា "លោកនេះ ត្រូវវិទ្យា-សាស្ត្របើកហើយ សង្ខារណាដែលគេនិយាយថា រលីង ជាប់ជិតស្និទ្ធបិតបេរ ជុំគាន់, នោះបែរទៅជាគ្រើមៗ រហាលៗពុកផុយ ដាច់ចេញពីគ្នា ឆាកលោកដែលវិទ្យាសាស្ត្របើកបង្ហាញនេះ លែងបិទទៅវិញហើយ" ។ ដំណើរនេះ កាលដែលព្រះសម្មាសម្ពុទ្ធបានផ្សាយថា ព្រះអង្គបានត្រាស់ដឹងហើយ ទ្រង់ក៏ប្រកាសថា ទ្រង់រកផ្លូវឃើញហើយ ផ្លូវទៅកាន់សិរីដ្ឋាននេះ គឺថាគេបើកហើយ មិនមានពិធីបន់ស្រន់បួងសួង

សូត្រស្តីទេ ផ្លូវនេះគឺវត្តប្រតិបត្តិ ដូចពុទ្ធតម្រាស់ដែលត្រាស់ចំពោះ សហម្បតិព្រហ្មថា៖ "ទ្វារនៃព្រះនិព្វាននោះតថាគតបើកហើយ សត្វទាំងឡាយណា មានសោតបសាទ សត្វទាំងឡាយនោះចូរបញ្ចេញសទ្ធាមកចុះ, ម្នាលមហាព្រហ្ម! តថាគតមិនទាន់សំដែងធម៌ជាធម៌ដ៏ឧត្តម ជាធម៌ដែលតថាគតបេះស្អាតក្នុងសំណាក់មនុស្សទាំងឡាយ ដោយសេចក្តីសំគាល់ក្នុងការលំបាកនោះទេ" ។ មួយទៀត ទ្រង់ប្រកាសថា "តថាគតគ្រាន់តែជាអ្នកប្រាប់ផ្លូវ" ដូចជាទ្រង់ប្រកាសថា "នេះទុក្ខ, នេះផ្លូវនាំឲ្យកើតទុក្ខ នេះព្រះនិព្វានជាឋានរំលត់ទុក្ខ នេះផ្លូវនាំទៅកាន់ព្រះនិព្វានជាឋានរំលត់ទុក្ខ" ។ អ្នកប្រតិបត្តិតាមពាក្យប្រៀនប្រដៅព្រះអង្គ នឹងបើកលោក ឃើញធម៌តាមយថាភូតទស្សនញ្ញាណដូចព្រះអង្គ រួចបាកទុក្ខលោកបាន យកឈ្នះទុក្ខលោកបាន ជាជ័យជំនះទីបំផុតលែងត្រឡប់ចាញ់វិញ ។ ដូច្នេះ ព្រះពុទ្ធសាសនា ជាសាសនាឯកក្នុងលោក ឥតមានសាសនាណាប្រៀបផ្ទឹមបានឡើយ ។

ព្រះពុទ្ធជាម្ចាស់ជាកំពូលអ្នកប្រាជ្ញ ទ្រង់ប្រកាសសាសនាប្រដៅសាវកព្រះអង្គ ឲ្យបានជាកំពូលអ្នកប្រាជ្ញដូចព្រះអង្គ ។ ធម៌ដែលទ្រង់សំដែងហើយដោយប្រពៃ ហើយមិនមានលទ្ធិដទៃណាមួយប្រៀបផ្ទឹមស្មើបាន ។ ក្នុងសម័យពុទ្ធកាល និគណ្ឋនាដបុត្រ បានបញ្ជូនឧបាលិ-គហបតី ដែលជាសាវកប្រាជ្ញឆ្នើម ឲ្យទៅផ្ចាញ់ព្រះអង្គ ដោយបំណង

នឹងស្នូរប្រែស្នាកាប់ព្រះអង្គឲ្យនៅនឹងថ្កល់ ដូចជាគេកាប់ដៃជើងក្ដាម តែកាលណាបានចូលទៅដល់ជិតព្រះអង្គហើយសាកសួរដេញដោល បានតែពីរបីប្រែស្នាប៉ុណ្ណោះ ក៏ទាល់ប្រាជ្ញ បែរទៅជាប្រគល់កាយថ្វាយខ្លួនជាសាវកព្រះអង្គវិញ លែងមើលមើលក្រោយហេតុដល់និគណ្ឋនាដបុត្រក្អួតចេញឈាម ។ បើអ្នកណាល្បងរកហេតុផលដទៃទៀត ដោយចង់ឲ្យវិសេសជាងទៅទៀត អ្នកនោះនឹងក្អួតចេញឈាមដូចនាដបុត្រ ។

ព្រះសម្មាសម្ពុទ្ធ តាំងពីបានត្រាស់ដឹងមក ទ្រង់បំពេញពុទ្ធកិច្ចត្រាច់ពុទ្ធដំណើរ ត្រាស់សំដែងធម៌ទេសនាប្រោសសត្វលោក ៤៥ ព្រះវស្សាឥតឈប់សំរាកព្រះអង្គ ពុទ្ធវចនៈទាំងប៉ុន្មានដែលទ្រង់សំដែងក្នុងរវាង ៤៥ នេះ មានអត្ថជ្រៅឆ្ងាយទូលាយណាស់ មិនអាចនឹងសរសេរលើទំព័រទស្សនាវដ្ដីនេះឲ្យចប់ទេ ។ បើរួមពុទ្ធវចនៈ ៤៥ វស្សានេះលោកហៅថា ស្វាក្ខាតោ ភគវតា ធម្មោ ឬស្វាក្ខាតធម៌ ពុំនោះហៅថាព្រះនពលោកុត្តរធម៌បានដល់អដ្ឋង្គិកមគ្គ ៨ នឹងព្រះនិព្វាន ១ ។ ធម៌នេះជាអរិយបថ ដឹកនាំជនឲ្យចូលទៅកាន់ឋានឈ្នះទុក្ខ ជាផ្លូវត្រង់ ធ្វើចិត្តសត្វឲ្យត្រជាក់ស្ងប់ត្រេកក្សាន្ត ជាធម៌ប្រណីត ជាធម៌ស្រោចស្រង់សត្វដាក់ដល់សិវឋានជាទីរលត់ទុក្ខ ។ នរជនណាមួយប្រតិបត្តិតាមដោយប្រពៃហើយ ឃើញធម៌ច្បាស់ដោយខ្លួនឯង បានទទួលផលមិនបាច់ចាំកាល អាចហៅជនដទៃឲ្យមកមើលផលដែលខ្លួនធ្វើពិសោធន៍ហើយ អាច

បង្អោនធម៌ចូលមកតំកល់ទុកក្នុងចិត្តបាន វិញ្ញូជនគប្បីដឹងប្រត្យក្សដោយខ្លួនឯង ឥតសង្ស័យឡើយ ។ នេះ ពុទ្ធសាសនា ។ បើពោលឲ្យខ្លីមាន ៣ ប្រការ គឺៈ ១– ទ្រង់ប្រដៅមិនឲ្យធ្វើអាក្រក់ ២– ទ្រង់ប្រដៅឲ្យធ្វើល្អ ៣– ទ្រង់ប្រដៅឲ្យធ្វើចិត្តស្អាតបរិសុទ្ធ ចាត់ជាវិន័យ ៥ គម្ពីរ ជាព្រះសូត្រ ៥ គម្ពីរ ជាព្រះអភិធម្ម ៧ គម្ពីរ ជាខ័ន្ធ ៨៤០០០ ព្រះធម្មក្ខ័ន្ធ ។ នេះ ពុទ្ធសាសនា ។ បើពោលឲ្យខ្លីតទៅទៀតមាន ២ ប្រការ គឺៈ ១– ធម៌ដែលត្រូវលះបង់ គឺធម៌អកុសល ; ២– ធម៌ដែលត្រូវចំរើនគឺធម៌ជាកុសល ។ នេះ ពុទ្ធសាសនា ។

ព្រះពុទ្ធសាសនាគឺអ្វីនោះ អ្នកអានទាំងឡាយគង់ជ្រាបច្បាស់ចាកពុទ្ធប្បវត្តិដែលបានស្រង់គោលសំខាន់ៗ ជូនខាងលើមកហើយថា ពុំមែនជាសេចក្តីពិតដែលបានមកចាកការបើកបង្ហាញប្រាប់ដោយឯកឯង ដូចការយល់សប្តិ ឬចាកការបញ្ចូលចិត្តឲ្យយល់ដូច្នោះទេ គឺ ជាសេចក្តីពិតព្រះបរមគ្រូជាម្ចាស់បានខះខំស្វែងរកជាច្រើនឆ្នាំ សេចក្តីពិតចេញចាកការពិសោធន៍គ្រប់យ៉ាង ហើយសេចក្តីពិតនោះព្រះអង្គមិនបានបង្ខំឲ្យជនបក្កកជឿទេ ទ្រង់ឲ្យពិចារណា ឲ្យពិសោធខ្លួនឯងតាមមាគ៌ាដែលទ្រង់បានបង្ហាញហើយ ព្រោះជាសេចក្តីពិតដែលមានជាធម្មតាឥតបដិសេធបាន ជាអកាលិកធម៌ ។ មួយវិញទៀត ធម៌ព្រះពុទ្ធ ពុំមែនជាធម៌សំរាប់ជួយស្រោចស្រង់សត្វឯកឯងទេ ជាធម៌សំរាប់ប្រតិបត្តិដោយខ្លួនឯង ដើម្បីប្រយោជន៍ចំពោះខ្លួនឯង ។ ភិក្ខុ ប៉ាង - ខាត់

# សាសនាក្នុងប្រទេសកម្ពុជា

សាសនាក្នុងប្រទេសកម្ពុជា  រាប់តាំងពីពេលដែលខ្មែរបានមកតាំងឥស្សរភាព  រហូតមកដល់សព្វថ្ងៃនេះ  បើនឹងកំណត់ទៅតាមលក្ខណៈនឹងហេតុការណ៍ផ្សេងៗ ដែលប្រព្រឹត្តទៅតាមសម័យនោះៗ អាចចែកបានជា ៣ សម័យ  គឺទី ១ សម័យនគរភ្នំ, ទី ២ សម័យនគរធំ, ទី ៣ សម័យឧត្តុង្គ  ។  ទាំង ៣ សម័យនេះ  មានរបៀបរបបយ៉ាងណា  គប្បីជ្រាបដូចអធិប្បាយតទៅនេះ :-

## បរិច្ឆេទទី ១

## សាសនាសម័យនគរភ្នំ

ភូមិភាគនៃប្រទេសកម្ពុជានេះ  មុនដែលជាតិខ្មែរមកតាំងឥស្សរ-ភាពនោះ  មានមនុស្សជាតិមកតាំងជាប្រទេសរួចទៅហើយ  ពោលដោយចំពោះ  គឺជាតិជ្វា  តែក្នុងសម័យជ្វានោះ  មិនប្រាកដថា  មានសាសនាអ្វីជាមាំមួននៅឡើយទេ  មានតែការរាប់អានទេពារក្ស ជាសរណៈប្រចាំជីវិត ។  លុះមកដល់ពុទ្ធសតវត្សទី ៧  មានជាតិខ្មែរ ១ ពួកបានចេញចាកប្រទេសកុរុរដ្ឋដែលជាប្រទេសដើមរបស់ខ្លួន  សឹងតាំងនៅក្នុងប្រទេសឥណ្ឌាភាគខាងត្បូង  នាំគ្នាចុះមកតាំងឥស្សរភាពនៅប្រទេសនេះ  គ្របលើជាតិជ្វាដែលតាំងមកមុន  បានទាំងនាំយកសាសនាព្រាហ្មណ៍  នឹងព្រះពុទ្ធសាសនា  មកប្រតិស្ឋានក្នុងប្រទេសថ្មីនេះផង

សឹងមានបុរាណវត្ថុ ដូចយ៉ាងទេវរូប ដែលធ្វើអំពីសម្រិទ្ធិ-ថ្ម និងប្រាង្គទេវស្ថាន ដែលធ្វើអំពីឥដ្ឋនិងព្រះពុទ្ធរូបជាដើមនៅដេរដាសដរាបដល់សព្វថ្ងៃនេះ ៗ ខនេះសមដូចសេចក្ដីកត់ហេតុដ៏មាននៅក្នុងពង្សាវតារចិនឈ្មោះណាន់ត្សីជូ និងលាំងជូ ថា អារ្យធម៌កលិង្គបានផ្សាយមកក្នុងដែនឥណ្ឌូចិន (=សុវណ្ណភូមិ) មានវិជ្ជាផ្សេងៗ ផ្សាយចូលមកគ្របលើវិជ្ជាស្រុកអាយ ជាច្រើនយ៉ាង គឺវិជ្ជាអក្សរសាស្ត្រ ភាសាសំស្ក្រឹត សាសនា លទ្ធិទំនៀម វិធីបូជា និងវិជ្ជាចិត្រកម្ម ៗលៗ ក្នុងខនេះយើងអាចកាប់រងយ៉ាងពេញទី ថាពិតដូច្នេះ អ្នកដែលនាំអារ្យធម៌ឥណ្ឌៀមកផ្សាយនៅដែនដីអាយនេះ គឺជាតិខ្មែរ ៗ អាស្រ័យជាតិខ្មែរក្នុងសម័យនោះមានអារ្យធម៌ខ្ពង់ខ្ពស់ និងមានឥទ្ធិពលជាងជាតិអ្នកស្រុកអាយ ទើបអាចតាំងឥស្សរភាព ហើយនិងគ្រប់គ្រងជាតិអ្នកស្រុកអាយបានទាំងអាចញ៉ាំងជាតិអ្នកស្រុកអាយ ឲ្យបំរើនរុងរឿងដោយអារ្យធម៌នោះផង ៗ ដោយហេតុនេះ ទើបមានធាយាថា "ខ្មែរជាតិឥណ្ឌៀទី ២ នៅក្នុងដែនសុវណ្ណភូមិ ជាដែនកណ្ដាលនៃអារ្យធម៌" ទំនងដូចជាតិរ៉ូមដ៏ជាដែនកណ្ដាលនៃអារ្យធម៌ក្រិក ៗ

សាសនាក្នុងសម័យនគរភ្នំ (ហ្វូណន) មានតែ ២ យ៉ាងគឺ សាសនាព្រាហ្មណ៍ និងព្រះពុទ្ធសាសនា ៗ ក្នុងសាសនាព្រាហ្មណ៍ តាមគោលដើម ឃើញដូចជាគេកប់អានព្រះជាម្ចាស់តែ ១ អង្គគឺព្រះព្រហ្ម,

សម័យក្រោយតមក គេបានបញ្ចូលព្រះ ២ អង្គថែមទៀត ទៅជា ៣ អង្គគឺព្រះព្រហ្ម ១ ព្រះសិវៈ (ឥសូរ.) ១ ព្រះវិស្ណុ (នារាយណ៍) ១.(១) តែសម័យនគរភ្នំគេច្រើនសាងរូបព្រះហរិហរទុកគោរព គឺធ្វើជារូបមានជើង ២ ដូចរូបមនុស្សធម្មតា តែដងខ្លួនមាន ៣ ភាគដូចមនុស្សម្នាក់ពាកូន ២ នៅបង្កេះសងខាង ។

បំណែកឯព្រះពុទ្ធសាសនាក្នុងសម័យនេះ មានតែលទ្ធិស្ថវីរៈ (ហីនយាន) ១ យ៉ាង លទ្ធិមហាយាន មិនទាន់ផ្សាយមកដល់នៅឡើយ ព្រះពុទ្ធសាសនាបែបនេះ ផ្សាយត្រង់ពីឥណ្ឌាមកតែម្តង ដោយខ្មែរយើងជាអ្នកនាំមកផ្សាយខ្លួនឯងក៏មាន ផ្សាយចូលមកពីខាងប្រទេសមនក៏មាន ។ តែក្នុងជាន់ដើម គង់មិនសូវរុងរឿងប៉ុន្មាន, លុះមកដល់ឆ្នាំ ព. ស. ៩៥៦ ក្នុងរជ្ជកាលព្រះបាទបន្ទុនៈប្រាកដជា ទ្រង់បានទទួលគម្ពីរព្រះត្រៃបិដកពីលង្កា តែការបានមកនេះ ដោយទ្រង់ឲ្យទៅស្វែងរកមក ឬដោយមានអ្នកណាទីមួយនាំមកថ្វាយ មិនឃើញមានពោលដល់ ។ ទោះបីយ៉ាងណាក៏ដោយ ការបានព្រះត្រៃបិដកគ្រានេះ រាប់ថាជាមង្គលលាភដ៏ខ្ពង់ខ្ពស់របស់ខ្មែរ ។ ព្រះបាទបន្ទុនៈទ្រង់ជាអគ្គសាសនូបត្ថម្ភ ចាប់តាំងពីរជ្ជកាលនេះទៅ ព្រះពុទ្ធសាសនាក៏សន្សឹមៗ ចំរើនដោយលំដាប់ ។

---

១ អ្នកចង់ជ្រាបសេចក្ដីពិស្ដារ ចូរមើលរឿងសាសនប្រវត្តិ ដែលបោះពុម្ពនៅក្នុងកម្ពុជសុរិយា មុននេះ ។

កន្លងមកដល់ក្នុងរជ្ជកាលព្រះបាទកោណ្ឌញ្ញជ័យវរ្ម័ន ដែលសោយ-រាជ្យក្នុងរវាងឆ្នាំ ព.ស ១១៣ ដល់ ១០៥៤ ទ្រង់ជាមហារាជាធិរាជ បានពង្រីកព្រះរាជអាណាចក្រឲ្យធំទូលាយក្រៃលែងជាងរជ្ជកាលណាៗ ទាំងអស់ ទ្រង់បានទំនុកបម្រុងប្រទេសជាតិឲ្យបានរុងរឿង ទាំងផ្លូវគតិលោក ទាំងផ្លូវគតិធម៌ ។ ព្រះពុទ្ធសាសនាក្នុងរជ្ជកាលនេះ បានចំរើនយ៉ាងខ្ពស់ ខនេះសមដូចសេចក្ដីកត់ហេតុ នៅក្នុងពង្សាវតារចិនថា "ក្នុងប្រទេសរបស់ព្រះបាទកោណ្ឌញ្ញជ័យវរ្ម័ន មានព្រះអារាមខាងព្រះពុទ្ធសាសនាដេរដាស" ។ គ្រានោះ មានព្រះមហាថេរ ២ អង្គ គឺ សក្យនាគសេន ១ ព្រះមហាសង្ឃបាល ១ ជាអ្នកប្រាជ្ញធំទ្រទ្រង់នូវព្រះត្រៃបិដកយ៉ាងបរិបូណ៌ ។ ព្រះសក្យនាគសេនមកពីឥណ្ឌា, ព្រះសង្ឃបាលកើតនៅស្រុកអាយនេះ ហើយប្រហែលជាទ្រង់តំណែងជា "ព្រះសង្ឃនាយក" ផង ។

មកក្នុងឆ្នាំ ព.ស. ១០២៧ ព្រះបាទកោណ្ឌញ្ញជ័យវរ្ម័នមហារាជ ទ្រង់ត្រាស់និមន្តព្រះសក្យនាគសេន ឲ្យនាំរាជសារនិងរាជបណ្ណាការ ទៅថ្វាយស្ដេចប្រទេសចិន ដើម្បីសុំចងសម្ពន្ធមេត្រីភាព ស្ដេចប្រទេសចិនក៏ព្រមទទួលចងសម្ពន្ធមេត្រីភាពផង ព្រមទាំងបានផ្ញើរាជសារ និងរាជបណ្ណាការមកថ្វាយតបវិញជាមួយនឹងព្រះសក្យនាគសេននោះផង(១)

• រាជបណ្ណាការនេះ មិនបានមកដល់ព្រះបាទកោណ្ឌញ្ញជ័យវរ្ម័នទេ ដោយត្រូវទាហានស្ដេចចាម្ប៉ាប្លន់យកអស់ទៅ ។

# ព្រះពុទ្ធសាសនាលទ្ធិស្ថវីរៈផ្សាយទៅប្រទេសចិន

ក្រោយពីនោះមក ២០ ឆ្នាំ គឺក្នុងឆ្នាំ ព.ស. ១០៤៦ ស្ដេចប្រទេសចិនបានតែងរាជទូត ឲ្យនាំរាជសារនឹងរាជបណ្ណាការមកថ្វាយ ព្រះបាទ-គោណ្ឌញ្ញជយវរ្ម័ន មហារាជ ដើម្បីសូមព្រះសង្ឃពួកទក្ខិណនិកាយទៅប្រកាសផ្សាយព្រះពុទ្ធសាសនាលទ្ធិស្ថវីរៈនៅប្រទេសចិន ព្រោះនៅប្រទេសចិនក្នុងពេលនោះ មានព្រះពុទ្ធសាសនាទៅដល់ហើយតែលទ្ធិមហាយាន ១ យ៉ាង ឯលទ្ធិស្ថវីរៈឬហីនយាន មិនទាន់ដែលផ្សាយទៅដល់ទេ ការដែលស្ដេចចិនសុំមកយ៉ាងនេះ ក៏ដោយទ្រង់បានជួបនឹងព្រះសក្យនាគសេនក្នុងកាលដែលលោកនិមន្តទៅក្រុងចិន កើតសេចក្ដីជ្រះថ្លាក៏ជួញព្រះហឫទ័យចង់ឲ្យព្រះពុទ្ធសាសនាបែបនេះ បានទៅផ្សាយនៅប្រទេសចិនផង ។

ព្រះបាទគោណ្ឌញ្ញជយវរ្ម័ន កាលទ្រង់បានទទួលព្រះរាជសារស្ដេចក្រុងចិនហើយ ត្រាស់ប្រឹក្សានឹងគណៈសេនាបតី បានព្រមព្រៀងចាត់ព្រះសង្ឃឲ្យទៅតាមសុំ ។ គ្រានោះ ទ្រង់បានអារាធនា ព្រះមហាសង្ឃ-បាលត្ថេរ ឲ្យទៅប្រកាសព្រះពុទ្ធសាសនាលទ្ធិស្ថវីរៈនៅប្រទេសចិន ។ ព្រះមហាសង្ឃបាលត្ថេរបានទៅប្រទេសចិនជាមួយរាជទូតចិន លោកបានបង្រៀនបរិយត្តិធម៌ និងប្រកាសផ្សាយព្រះពុទ្ធសាសនាលទ្ធិស្ថវីរៈនៅប្រទេសនោះអស់វេលា ៤ ឆ្នាំគត់ ទើបនិមន្តត្រឡប់មកប្រទេសខ្មែរវិញ ។

រឿងនេះ មានប្រាកដនៅក្នុងប្រវត្តិសាស្ត្រខ្មែរ រាប់ថាជាកិត្តិយស ១ យ៉ាងរបស់ខ្មែរយើង ។

ព្រះមហាក្សត្រិយ៍ទាំងឡាយដែលសោយរាជ្យ ក្នុងលំដាប់តទៅរហូតដល់ព្រះបាទឦសានវរ្ម័ន ដែលសោយរាជ្យក្នុងរវាងឆ្នាំ ព. ស. ១១៥ ដល់ ១១៧៣ សុទ្ធសឹងតែទ្រង់គោរពរាប់អានព្រះពុទ្ធសាសនាយ៉ាងមាំមួន ចំពោះព្រះបាទឦសានវរ្ម័ននេះ ប្រាកដតាមសិលាចារឹកជាភាសាខ្មែរ ដែលទ្រង់ឲ្យចារឹកទុក ក្នុងឆ្នាំមហាសករាជ ៥៣៣ មានសេចក្តីរាយរាប់មុខរបស់ដង្វាយ ដែលទ្រង់បានថ្វាយជាពុទ្ធបូជានៅក្រុងនគរបុរី នឹងថា ទ្រង់តែងធ្វើព្រះសង្ឃទានរាល់ៗថ្ងៃសីលផង ។ នេះជាភស្តុតាងក្នុង១ដែលថាព្រះមហាក្សត្រិយ៍ទាំងឡាយ ទ្រង់គោរពរាប់អានព្រះពុទ្ធសាសនា ។

ក្រោយរជ្ជកាលព្រះបាទឦសានវរ្ម័នមក ប្រទេសកម្ពុជាកើតវិបរិតប្រែប្រួលជាយ៉ាងខ្លាំង រហូតដល់ផុតសម័យនគរភ្នំ ដោយហេតុពួកក្សត្រិយ៍កើតច្បាំងគ្នាឯងឡើងក្នុងប្រទេសជាញឹកញយ អំពីនោះមកការព្រះពុទ្ធសាសនាក៏រៀរេយចុះ ។

ចប់បរិច្ឆេទទី ១ សម័យនគរភ្នំ ។

# អគ្គញ្ញសូត្រ

(តមកនឹងចប់)

ដោយមានពួកសត្វខ្លះ ក្នុងបណ្ដាសត្វទាំងនោះ បានប្រព្រឹត្តកាន់នូវមេថុនធម្ម ហើយប្រកបការងារផ្សេងៗ គ្នា ទើបកើតមានអក្ខរៈថា "វេស្សៈវេស្ស" ដូច្នេះ ។ បន្ទាប់មក, ដោយមានទំនងដូចខាងលើនេះដែរ, ទើបកើតមានអក្ខរៈថា "សុទ្ទៈ សុទ្ទៈ" ដូច្នេះ ។ ការកើតឡើងនៃអក្ខរៈជាច្បាប់ចាស់ ដល់វេស្សមណ្ឌលនិងសុទ្ទមណ្ឌលទាំងនោះ ដូចគ្នានឹងសត្វទាំងឡាយដទៃដែរ មិនខុសគ្នាទេ, ហើយកើតឡើងដោយធម៌តែម្យ៉ាង មិនមែនដោយខុសធម៌ទេ ។

ជួនកាលមានក្សត្រខ្លះ, ព្រាហ្មណ៍ខ្លះ, វេស្សៈខ្លះ សុទ្ទៈខ្លះ មិនពេញចិត្តនឹងធម៌របស់ខ្លួន តិះដៀលធម៌របស់ខ្លួន ហើយចេញចាកផ្ទះសម្បែងចូលមកកាន់ផ្នួសដោយបំណងថា "អាត្មាអញនឹងធ្វើជាសមណៈ" ដូច្នេះក៏មាន ។ ព្រោះហេតុនោះឯង ការកើតឡើងនៃសមណមណ្ឌល ក៏បានមានប្រាកដឡើងដោយសារមណ្ឌលទាំង ៤ នេះឯង (ខត្តិយមណ្ឌល, ព្រាហ្មណមណ្ឌល, វេស្សមណ្ឌល សុទ្ទមណ្ឌល) ។

ក្នុងមណ្ឌលទាំងអស់នេះ, មានក្សត្រខ្លះ ព្រាហ្មណ៍ខ្លះ, វេស្សៈខ្លះ, សុទ្ទៈខ្លះ, សមណៈខ្លះ, ប្រព្រឹត្តអាក្រក់ដោយកាយ វាចា ចិត្ត ជាមិច្ឆាទិដ្ឋិតែម្យ៉ាងក៏មាន ។ ក្រោយនេះ, លុះធ្វើកាលកិរិយាក្ស័យទៅ ក៏រមែងទៅ

កើតក្នុងកំណើតសត្វតិរច្ឆាន, ប្រេតវិស័យ អសុរកាយ និងនរក ព្រោះតែអំពើអាក្រក់នោះឯង ។ មានក្សត្រខ្លះ, ព្រាហ្មណ៍ខ្លះ, វេស្សៈខ្លះ សុទ្ទៈខ្លះ, សមណៈខ្លះ, ប្រព្រឹត្តល្អដោយកាយ វាចា ចិត្ត ប្រកាន់នូវសម្មាទិដ្ឋិតែម្យ៉ាង ក៏មាន ។ ពួកនេះ លុះអស់ជីវិតទៅ រមែងបានទៅកើតក្នុងសុគតិភពសួគ៌ទេវលោក ។ មានក្សត្រខ្លះ, ព្រាហ្មណ៍ខ្លះ, វេស្សៈខ្លះ, សុទ្ទៈខ្លះ, សមណៈខ្លះ, ជួនកាលប្រព្រឹត្តធ្វើអំពើទាំងពីរចំណែកលាយឡំគ្នា ទាំងល្អ ទាំងអាក្រក់ ដោយកាយ វាចា ចិត្ត ។ ពួកនេះ លុះរលត់ជីវិតទៅ រមែងបានទទួលនូវសេចក្ដីសុខខ្លះ សេចក្ដីទុក្ខខ្លះ ព្រោះតែខ្លួនបានប្រព្រឹត្តធ្វើអំពើទាំងពីរច្របូកច្របល់គ្នា ។ មានក្សត្រខ្លះ, ព្រាហ្មណ៍ខ្លះ, វេស្សៈខ្លះ, សុទ្ទៈខ្លះ, ជាអ្នកសង្រួមកាយ វាចា ចិត្ត ប្រព្រឹត្តត្រឹមត្រូវ ខិតខំចំរើននូវពោធិបក្ខិយធម៌ទាំង ៧ ក្នុង រមែងបរិនិព្វានក្នុងបច្ចុប្បន្ននេះ ក៏មាន ។

ក្នុងទីបំផុត. ព្រះសម្ពុទ្ធទ្រង់ត្រាស់ចំពោះសាមណេរទាំង ២ រូបថា ម្នាលវាសេដ្ឋៈនិងភារទ្វាជៈ ក៏បណ្ដាវណ្ណៈទាំង ២ នេះ វណ្ណៈណាមួយបានបួសជាភិក្ខុ បានសម្រេចអរហត្តកាត់អស់កិលេសតណ្ហារលីងហើយ ព្រោះបានត្រាស់ដឹងដោយប្រពៃ, វណ្ណៈនោះ ទើបចាត់ជាបុគ្គលប្រសើរលើសគេទាំងអស់ ដោយត្រូវតាមធម៌ពិត ព្រោះធម៌ជាគុណជាតប្រសើរបំផុត ក្នុងប្រជុំជនទាំងក្នុងបច្ចុប្បន្ននិងបរលោក ។ ដំណើរ

នេះសូម្បីព្រហ្មឈ្មោះសនង្កុមារ ក៏បានពោលសរសើរទុកថា "ខត្តិយៈជាជាតិប្រសើរបំផុតក្នុងប្រជុំជន, តែអ្នកដែលបរិបូណ៌ដោយវិជ្ជានឹងចរណៈប្រសើរបំផុតទៅទៀត ក្នុងពួកមនុស្សនឹងទេព្តា" ។ ពាក្យសរសើរនេះល្អពីរោះពន់ពេក ប្រកបដោយប្រយោជន៍ច្រើន ទោះទាំងតថាគតក៏យល់ព្រមតាមហើយ ក៏បានពោលទុកមកដូចគ្នាយ៉ាងនេះដែរ ។

---

សេចក្តីក្នុងអគ្គញ្ញសូត្រនេះ នាំឲ្យមជ្ឈជនខ្លះយល់ថា "ព្រះពុទ្ធជាអ្នកបដិវត្តសំខាន់មួយ ទ្រង់រៀបចំលំដាប់ក្នុងសង្គមជាថ្មី បំបាត់មិនឲ្យមានវណ្ណៈគឺខត្តិយៈ១ ព្រាហ្មណ៍១ វេស្សៈ១ សុទ្ទៈ១ ហើយមិនឲ្យប្រកាន់ជាតិ-ត្រកូល" នេះជាសេចក្តីយល់ខុស ។ ព្រះពុទ្ធពុំមែនជាអ្នកសង្គមវិទ្យាទេ ទ្រង់ជាអ្នកសីលធម៌ពិតៗ ។ ព្រះអង្គគ្រាន់តែបញ្ជាក់ប្រាប់អំពីដើមកំណើតនៃវណ្ណៈទាំងឡាយ ដែលអ្នកផងបានសន្មតទុកមកហើយតាមធម្មតាលោក ដើម្បីបដិសេធនូវអំនួតរបស់ពួកព្រាហ្មណ៍ប៉ុណ្ណោះ ដោយការបង្ហាញឲ្យឃើញតាមពិតថា ការប្រសើរខ្ពង់ខ្ពប់នោះ ពុំមែនជាបុព្វសិទ្ធិវិសេសចំពោះវណ្ណៈណាមួយដាច់ដោយឡែកឡើយ ពុំចំពោះតែពួកព្រាហ្មណ៍ពីកំណើតនោះទេ គឺចំពោះតែនរណាទោះជាវណ្ណៈណានៅក្នុងឋានៈណាក៏ដោយ ដែលកាត់អស់កិលេស-តណ្ហាទាំងពួងហើយនោះឯង ។

ញុង-សៀង

# លោកវិចារ

បើយើងពិចារណាលោកសន្និវាសនេះ យើងអាចឃើញព្រះសុរិយា ចាំងវែងលើមេឃា រះពីខាងកើតអស្តង្គតទៅខាងលិច សព្វទិនទិវារាត្រី ថ្ងៃ-យប់ៗថ្ងៃ; ពពកស, ក្រហម, ខៀវ, ស្រកានាគអណ្តែតត្រសែត ពពួនពពាក់លើនភាល័យទៅគ្រប់ទិសតំបន់, ផនដាតិខៀវ, ក្រហម, លឿង, ស កើតស្លាប់ៗកើត គ្រប់ប្រទេសភូមិភាគ, និគមជនបទ; សកុណសត្វ, ជាតិវារី, សត្វព្រៃ-ស្រុកខ្វះត្រាច់រកអាហារ, ខ្វះយំស្រែក តាមស្រុកភូមិ; រុក្ខាលតាវល្លិដុះស្រោងស្រោងតាមព្រៃភ្នំនិគមជនបទ លំអដោយបុប្ផ រីកស្គុះស្គាយមានពណ៌គ្រប់យ៉ាង; ទឹកជ្រោះហូរចេញពី គុហាភ្នំមានសព្ទសូរពីរោះគួរឲ្យសរនា កើតទៅជាស្ទឹង ទន្លេ-សមុទ្រ ឥតឈប់ឈរៈសោះឡើយ; កេត្រាពាណិជ, នាវាធំៗ ធ្វើកាត់មហា សាគរដឹកទំនិញទៅលក់ឯប្រទេសនាយ; រថយន្ត, អយស្ម័យយានបរ ចេញចូលគ្រប់ផ្លូវ ដឹកនាំពួកអ្នកដំណើរទៅគ្រប់ទីកន្លែង ។

ដើម្បីអ្វី? ដើម្បីរកសេចក្តីសុខ ។ លោកទាំងមូលប្រាថ្នាសេចក្តី សុខ ម្តេចក៏បានទុក្ខទៅវិញ? លោកទាំងមូលប្រាថ្នាសេចក្តីស្រួល ម្តេច ក៏បានសេចក្តីលំបាកទៅវិញ? លោកទាំមូលប្រាថ្នាព្រះនិព្វាន ម្តេចក៏ធ្លាក់ ទៅរងទុក្ខក្នុងនរកវិញ? ។

ព្រោះហេតុអ្វី? ព្រោះសត្វលោកប្រព្រឹត្តទុច្ចរិត, សត្វលោកប្រកប ដោយលោភៈ ទោសៈ មោហៈ ជាកិលេសដេកត្រាំនៅក្នុងសន្តាន,

សត្វលោកប្រកាន់ថា អញធំ, អញប្រសើរជាងគេ ជាដើម ៗ ការប្រព្រឹត្តទុច្ចរិតពាលបាបអកុសល នាំសេចក្ដីទុក្ខមកឲ្យ; លោភៈ ទោសៈ មោហៈ នាំឲ្យមនុស្សលួចប្លន់កាប់សម្លាប់ព្យាបាទគ្នាទៅវិញទៅមក, លោភចង់បានទ្រព្យសម្បត្តិអ្នកដទៃមកជារបស់ខ្លួន មិនចេះឆ្អែតឆ្អន់ ដូចសុភាសិតថា "បានហើយចង់បានទៀត ធ្វៀតហើយធ្វៀតមិនគ្នាន់គ្នេរ មិនឲ្យខ្លួនទំនេរ ទ្រព្យលោភមិនចេះឆ្អែត" ៗ បើដូច្នេះ, លោភៈ ជាហេតុនាំឲ្យកើតទុក្ខ ៗ អ្វីជាហេតុឲ្យកើតសុខ? អលោភៈ ការមិនលោភ គឺស្វែងរកធនធានតាមសម្មាអាជីវ ស្វែងរកបានមកហើយ ត្រូវលៃលកធ្វើការកុសលជាប្រយោជន៍ដល់សាសនាខ្លះ, ដល់ជាតិខ្លះ ៗ ព្រះសម្មាសម្ពុទ្ធព្រះអង្គមិនមែនហាមមិនឲ្យប្រជាជនរកទទួលទាន ធ្វើពាណិជ្ជកម្ម, ក្សេត្រកម្ម ឬកសិកម្មទេ, ព្រះអង្គទូន្មានឲ្យព្យាយាមរកភោគទ្រព្យឲ្យបានច្រើន, តែបើបានភោគទ្រព្យបរិបូណ៌ហើយ ត្រូវលះទ្រព្យនោះចេញ ដោយការចែកទ្រព្យទុកការពារអាសន្ន, ទុកធ្វើបុណ្យ, ចិញ្ចឹមគ្រួសារជាដើម គឺត្រូវបំបាត់សេចក្ដីកំណាញ់ស្វិតស្វាញចេញពីសន្ដាន ដោយការឲ្យទាន ព្រោះទាននេះជាឱសថទិព្វសម្រាប់កែរោគកំណាញ់, កែរោគលោភ, ការឲ្យទាននោះ តាំងពីសាមីទានរហូតដល់សង្ឃទាន ធម្មទាន ដូចជាចូលជាសមាជិកក្នុងសមាគម ដើម្បីបណ្ដុះនូវធម៌សាមគ្គីរវាងមនុស្សជាតិ, ការបរិច្ចាគទ្រព្យសង់នូវមន្ទីរព្យាបាល

ពេគ, សាលារៀន, វត្តអារាមជាដើម ដើម្បីជាប្រយោជន៍ទូទៅឈ្មោះថា ជាកុសលមួយដ៏ប្រសើរ ។

ទោសៈ ដែលនាំមនុស្សឲ្យក្រោធខឹង រហូតដល់ព្យាបាទគំនុំគុំគួន, ពិឃាតគ្នាទៅវិញទៅមក នេះក៏ជាហេតុធ្វើសត្វឲ្យបានទុក្ខ ។ ទោសៈ នេះ ជាភ្លើងតែងតែបង្កាត់នូវខុសប្ដុគល់ឈើឲ្យឆេះរាលដាលទៅគ្រប់ អន្លើ សមដូចពុទ្ធភាសិតសំដែងនៅក្នុងគម្ពីរធម្មបទខុទ្ទកនិកាយថា: “នត្ថិ ទោសសមោ កលិ ឥតមានទោសដទៃស្មើដោយទោសៈ ឡើយ” ។ មនុស្សយើងតែងប្រកាន់ថា ខ្លួនប្រសើរវិសេសជាងគេ គ្មានអ្នកណាស្មើនឹងខ្លួន ឬថាលទ្ធិខ្លួនជាឧត្តុង្គឧត្តមជាងលទ្ធិអ្នកដទៃ ។ ការប្រកាន់បែបនេះជាហេតុឲ្យមានប្រណែននិន្ទា, ឲ្យមានយោបល់ទាស់ ខុសគ្នា ទៅជាប្រឆាំងប្រដែងគ្នា ឲ្យមានទោម-ស្សរៀងខ្លួន. ជា ហេតុឲ្យកើតទោសៈ។ នាំឲ្យធ្វើសង្គ្រាមយកចាញ់-ឈ្នះ មិនព្រមបន្ធូរ បន្ថយចិត្ត យកត្រូវជាខុសៗ ជាត្រូវ រហូតដល់ខ្លះឃើញតែទោសគេ, ទោសខ្លួនមើលមិនឃើញ ដូចជាពាក្យបុរាណភាសិតពោលថា: “ពាក្យ ចាស់ពាក្យពីព្រេង ទោសខ្លួនឯងមើលមិនយល់ ទោសគេតូចសោត សល់ មើលយល់ប៉ុននឹងភ្នំ” ។

ធម្មតាមនុស្សតែងប្រទះនូវអនិដ្ឋារម្មណ៍ គឺអារម្មណ៍មិនជាទីគាប់ ចិត្ត នាំឲ្យតូចចិត្ត, អាក់អន់ស្រពន់ចិត្ត; បើមិនប្រយ័ត្ន ភ្លើងគឺទោសៈ

នោះចេះទេ ទោសនឹងនាំឆេះដល់ចិត្តចេញទៅតាមមាត់តាមភ្នែក, ទៅជាក្រហមអវយវៈ ទៅជាក្តាប់ដៃស្ទុះក្រទឹក្រទាមានសភាពផ្សេងៗ, នាំបណ្តាលឲ្យដាល់តប់, ឲ្យជេរប្រទេចផ្តាសាជាពាក្យអាសគ្រាមមិនគប្បីរហូតដល់ទៅកាប់សម្លាប់គ្នាជាទីបំផុត ។ ព្រោះហេតុដូចនេះ បានជាព្រះសម្មាសម្ពុទ្ធទូន្មានទាយកទាយិកាកាន់សីល ។ សីលជាឱសថមួយសម្រាប់កែកោតទោសៈ ។ សីលនេះ, បើអ្នកណាបានកាន់ជាប់ជានិច្ច-កាល នឹងបានផលគឺការស្ងប់ រម្ងាប់នូវទោសៈឲ្យថយចុះ ជាហេតុឲ្យបានសេចក្តីសុខ ។

មោហៈ គឺសេចក្តីវង្វេង, កាន់ច្រឡំ, យល់ខុសជាត្រូវៗ ជាខុស, យល់សុខជាទុក្ខៗ ជាសុខ ។ ហេតុដែលឲ្យកើតមោហៈមកពីការមិនបានរៀនវិជ្ជា, ខ្វះការពិចារណារកហេតុផល, ខ្វះប្រាជ្ញា ដែលជាអាវុធសម្រាប់កាប់ផ្តាច់នូវវិចិកិច្ឆា គឺការសង្ស័យ ប្រៀបដូចជាមច្ឆជាតិវង្វេងភាន់ច្រឡំស្មានថា សំណាញ់នេះជាទីកន្លែងស្រួលសប្បាយ ដល់ចូលទៅក្នុងសំណាញ់នោះទើបរើបំរះមិនរួច សមដូចពុទ្ធភាសិតក្នុងធម្មបទខុទ្ទក-និកាយពោលថា "នត្ថិ មោហោ សមំ ជាលំ គ្មានសំណាញ់អ្វីស្មើដោយមោហៈទេ" ។ មោហៈជាសំណាញ់តែងបង់ក្រសោបអូសយកសត្វលោកគៀរទម្លាក់ទៅក្នុងអបាយភូមិទាំង ៤ ។ ដើម្បីបំបាត់នូវមោហៈត្រូវធ្វើសមាធិកម្មដ្ឋាន នឹងវិបស្សនាកម្មដ្ឋានដើម្បីនឹងធ្វើចិត្តឲ្យនឹងធឹង ជាហេតុឲ្យកើតបញ្ញាសម្រាប់ពិចារណារកផ្លូវត្រូវ-ខុសទៅតាមយថាភូត ។

បើតាមសេចក្ដីពណ៌នាខាងលើនេះ ឃើញថា លោភៈ ទោសៈ មោហៈជាឫសគល់នៃទុក្ខ; អលោភ ឫទាន, អទោសៈ ឫសីល, អមោហៈ ឫភាវនាជាឫសគល់នៃសុខ ៗ លោកនេះបើពិចារណាឲ្យច្បាស់លាស់, ពិតមែនតែប្រកបដោយ អនិច្ចំ, ទុក្ខំ, អនត្តា; ពិតមែនតែកើត, ចំរើន, វិនាសទៅតាមសង្ខារធម៌ ដែលជាមេជាងតាក់តែងៈ ពិតមែនតែមានឧបសគ្គមកកំផែង គឺអកុសលមូលទាំងបី, ក៏គង់អាចធ្វើដំណើរលឿនទៅមុខបានដែលហៅថា បដិសន្ធិ, វិវត្តន៍ ឫវឌ្ឍនធម៌របស់លោក ទៅតាមថ្នាក់, ខ្ពស់ទាប, រហូតដល់ប្រល័យកល្ប គឺវិនាសជាទីបំផុត ៗ លោកិ គឺមានអាកាសធាតុជាបុព្វហេតុ, ក្នុងអាកាសធាតុមានបរមាណូញីឈ្មោលតស៊ូគ្នាកើតឡើងជាព់យោធាតុ ៗ មានបរមាណូប្រាំងគ្នាទៅជាតេជោធាតុ ៗ នាំឲ្យកើតអាបោធាតុ ៗ នាំឲ្យកើតបថវីធាតុ ៗ នាំឲ្យកើតអវិជ្ជា ៗ នាំឲ្យកើតសង្ខារ ៗ នាំឲ្យកើតវិញ្ញាណ ៗ នាំឲ្យកើតនាមនឹងរូប ៗ នាំឲ្យកើតសឡាយតន ៗ នាំឲ្យកើតផស្ស ៗ នាំឲ្យកើតវេទនា ៗ នាំឲ្យកើតតណ្ហា ៗ នាំឲ្យកើតឧបាទាន ៗ នាំឲ្យកើតភព ៗ នាំឲ្យកើតជាតិ ៗ នាំឲ្យកើតជរាព្យាធិមរណៈ, ទាំងអស់នេះប្រមូលទៅមានកើតលោកខាងក្រៅ ១, លោកខាងក្នុង ១ ៗ គឺភពជាលោកខាងក្រៅ, សត្វដែលនៅក្នុងភព ជាលោកខាងក្នុង ៗ លោកទាំងពីរនេះ ធ្វើដំណើរទៅមុខជានិច្ច ទាំងយប់-ថ្ងៃគ្មានឈប់ឈរ គឺលោកចំរើនដោយវិជ្ជាជាច្រើន

បែប ៗ យ៉ាងដែលកើតមកពីប្រាជ្ញារបស់មនុស្សអាចពិចារណា ស្គាល់ខុស-ត្រូវ, យល់ចំរើនវិនាស ក៏រចនា ៗ កែឲ្យចំរើនទៅតាមកាលសម័យ ៗ សត្វលោកដែលប្រាថ្នាសុខ ហើយចេះតែប្រទះទុក្ខមកពីកាន់ប្រឡូកក្នុងអទ្ធា ៣ គឺៈអតីតទ្ធា ១, បច្ចុប្បន្នទ្ធា ១, អនាគតទ្ធា ១ ដែលបណ្ដាលមកពីអកុសលមូលទាំង ៣ នោះឯង ហើយច្រើនយកបច្ចុប្បន្នទ្ធាមកជាឡាក់គោល ក្រៅអតីតនិងអនាគត ក្រៅទាំងផ្លូវធម៌ដែលអាចនាំទ្រលោកឲ្យតាំងនៅជាស្ថាពរក្នុងសេចក្ដីសុខ, លោកនេះដល់ចំរើនពេញលក្ខណៈ ហើយក៏ត្រូវវិនាសវិញ ដែលគេហៅថា កល្បវិនាស ឬភ្លើងឆេះកល្ប ៗ ក្នុងពេលនោះ លោកចូលទៅក្នុងស្ថានភាពជាសំពកមួយគ្រាសិន, សត្វលោកក៏ផុតពីច្បាប់ឬបទបញ្ញត្តិ ព្រោះកាលណាលោករលាយ មនុស្សសត្វទាំងអស់ក៏រលាយដែរ គឺគេហៅថា លោកសូន្យ ៗ

ព្រោះហេតុដូច្នេះ, លោកវិលចុះឡើងទៅតាមច្បាប់កង់ចក្រ ឬបក្រដទៀត ៗ លុះត្រាតែសត្វលោករកលោកឃើញ, ស្គាល់លោកច្បាស់ ទើបយកវិបស្សនាបញ្ញាមកពិចារណាឲ្យដឹងច្បាស់ថា លោកនេះជាអនិច្ចំ ទុក្ខំ អនត្តា ហើយប្រកបទាន, សីល, ភាវនា អណ្ដែតផុតពីលើច្បាប់លោក លះបង់នូវលោភៈទោសៈមោហៈ ជាអកុសលមូល ទើបរចនាលោកនោះឲ្យទៅជាធម៌ អាចបានប្រទះនូវសេចក្ដីសុខដ៏ឧត្តមពោលគឺព្រះនិព្វានក្នុងទីបំផុត ៗ

ភ័យ - ប៊ុក

# សង្គហធម៌

ក្នុងលោកនេះ មនុស្សយើងនៅលោលត្រមង់ត្រមោចតែម្នាក់ឯងពុំបានទេ ត្រូវតែមានមិត្តភក្តិជួយទុកធុរៈគ្នាទៅវិញទៅមកទើបបានសេចក្តីសុខ ។ ការកៀរប្រមូលមហាជនឲ្យមូលមិត្តគ្នាឲ្យមានសាមគ្គីព្រមព្រៀងគ្នាជាធ្លុងមួយនោះ ត្រូវធ្វើទៅតាមគន្លងធម៌ ។ ព្រះពុទ្ធជាបរមគ្រូទ្រង់ត្រាស់សរសើរសង្គហធម៌ ថាជាធម៌សម្រាប់រួបរួមប្រជាជនឲ្យមូលមិត្តឲ្យមានសាមគ្គីព្រមព្រៀងគ្នា ។ ព្រោះហេតុនោះ សង្គហធម៌នេះឯងទើបឈ្មោះថាជាបវេណីធម៌ (ទំនៀមទម្លាប់) សម្រាប់ជនទូទៅក្នុងត្រកូលមួយៗ ក្នុងស្រុក នគរ ប្រទេសនីមួយៗ សង្គ្រោះស្រោចស្រង់ទំនុកបំរុងគ្នាទៅវិញទៅមក ដូចយ៉ាងមាតាបិតានឹងបុត្រធីតា, គ្រូអាចារ្យនឹងសិស្ស, ស្វាមីនឹងភរិយា, មិត្តសំឡាញ់នឹងមិត្តសំឡាញ់ផងគ្នា, ចៅហ្វាយនាយនឹងទាសកម្មករ, បព្វជិតនឹងគ្រហស្ថ ជាដើម សុទ្ធតែមានការៈត្រូវសង្គ្រោះគ្នាឬជួយឧបត្ថម្ភទំនុកបំរុងផង ដើម្បីគ្នាក្នុងកិច្ចធុរៈណាមួយ ដោយតិចក្តី ច្រើនក្តី តូចក្តី ធំក្តី ជាធម្មតា ។ កិច្ចជនដែលបានធ្វើសេចក្តីសង្គ្រោះគ្នាទៅវិញទៅមកយ៉ាងនេះ ឈ្មោះថាជាបុព្វការី (អ្នកធ្វើនូវឧបការៈមុន) ជាអ្នកសមគួរទទួលនូវសក្ការបូជារបស់កតញ្ញូកតវេទិបុគ្គល ព្រមទាំងជាអ្នកគួរគេគប់រកលើក

ដំកើងកូនហានៈខ្ពង់ខ្ពស់ ហើយនឹងមានកេរ្តិ៍ឈ្មោះពិរោះពិសាជាដើមថែមទៀតផង ។

ប្រសិនបើជនទាំងឡាយមានមាតាបិតានឹងបុត្រធីតាជាដើម មិនមានការប្រស្រ័យទាក់ទងគ្នា ឬមិនមានការសង្គ្រោះជួយដោះទុក្ខធុរៈគ្នាទៅវិញទៅមកទេ នោះមុខជានឹងមិនបានជាទីគោរពបូជា ជាទីស្រឡាញ់រាប់អាននៃគ្នានឹងគ្នាឡើយ ហើយសមនឹងបានសេចក្តីទុក្ខសោកសង្រេងសង្រែងកើតទីបំផុតគ្មានពុំខាន ។ ហេតុនេះឯងហើយបានជាព្រះសម្ពុទ្ធជាបរមគ្រូទ្រង់សំដែងសង្គហធម៌ ដែលជាឧបាយសម្រាប់ប្រមូលប្រជាជនទាំងឡាយឲ្យទៅឲ្យមូលមិត្រគ្នា ឲ្យមានសាមគ្គីព្រមព្រៀងគ្នា ឲ្យបានជាទីពេញចិត្តនឹងជាទីទំនុកទុកចិត្តគ្នាទៅវិញទៅមក ដើម្បីឲ្យបានសម្រេចប្រយោជន៍គ្រប់យ៉ាង ។ រីឯសង្គហធម៌នោះមាន ៤ យ៉ាង គឺ:

១ — ទាន: ការឲ្យទេយ្យវត្ថុដែលគួរឲ្យ;

២ — បិយវាចា: ការពោលពាក្យគួរឲ្យចង់ឮចង់ស្តាប់ ឬពាក្យជាទីស្រឡាញ់;

៣ — អត្ថចរិយា ការប្រព្រឹត្តអំពើជាប្រយោជន៍ដល់គ្នាទៅវិញទៅមក;

៤ — សមានត្តតា ការតាំងខ្លួនស្មើៗ ។

ដើម្បីជាគោលក្នុងរឿងនេះ សូមទាញពុទ្ធភាសិតដូចខាងក្រោម:

ទានញ្ច បិយវជ្ជញ្ច　　អត្ថចរិយា ច យា ឥធ
សមានត្តតា ច ធម្មេសុ　　តត្ថ តត្ថ យថារហំ
ឯតេ ខោ សង្គហា លោកេ　　រថស្សាណីវ យាយតោ
ឯតេ ច សង្គហា នាស្សុ　　ន មាតា បុត្តការណា
លភេថ មានំ បូជំ វា　　បិតា វា បុត្តការណា
យស្មា ច សង្គហា ឯតេ　　សមវេក្ខន្តិ បណ្ឌិតា
តស្មា មហត្តំ បប្បោន្តិ　　បាសំសា ច ភវន្តិ តេ ។

“ធម៌សម្រាប់សង្គ្រោះរបស់មនុស្សក្នុងលោកនេះ មាន ៤ យ៉ាង គឺ: ធ្វើទាន ១ ពោលពាក្យពីរោះ ១ ការប្រព្រឹត្តិតែខាងអំពើដែលមានប្រយោជន៍ ១ ការមានចិត្តស្មើក្នុងកុសលធម៌ទាំងឡាយ នឹងក្នុងបុគ្គលទាំងឡាយនោះៗ តាមសមគួរ ១ ធម៌ទាំងប៉ុណ្ណោះនេះរមែងប្រព្រឹត្តទៅក្នុងលោក ដូចជាខ្សែកចប់នៃរទេះ; ធម្មតារទេះ កាលបើមានខ្សែកចប់ ទើបអាចប្រព្រឹត្តទៅបាន បើមិនមានទេ ក៏មិនអាចនឹងប្រព្រឹត្តទៅបានឡើយ; ចំណែកខាងសត្វលោក កាលបើមានសង្គហធម៌ទាំងបួនប្រការនេះ ទើបប្រព្រឹត្តទៅបាន ជាបើមិនមានទេ ក៏មិនអាចប្រព្រឹត្តទៅបានឡើយ; ប្រសិនបើសង្គហធម៌ទាំង ៤ ប្រការនេះ មិនមានហើយ មាតាក្ដី បិតាក្ដី

ក៏មិនអាចបាននូវការបូជា ឬសេចក្តីរាប់អានអំពីកូនរបស់ខ្លួនឡើយ ។ អ្នកប្រាជ្ញទាំងឡាយតែងប្រព្រឹត្តធ្វើនូវសង្គហធម៌ទាំង ៤ ប្រការនេះដោយប្រពៃ ព្រោះហេតុនោះ បានជាលោកបានដល់នូវសេចក្តីចំរើននឹងសេចក្តីសរសើរអំពីប្រជុំជន” ។

១ — ទានៈ – ការចែករំលែកទេយ្យវត្ថុ ឬទ្រព្យសម្បត្តិរបស់ខ្លួនទំនុកបំរុងផ្គងផ្គើមដល់មនុស្សទាំងឡាយ ដោយអធ្យាស្រ័យប្រកបដោយមេត្តា ករុណា ហៅថា ទាន ។ ទាននេះ ជាទឹកបន្សាបឬជាចំណងសម្រាប់ចងមិត្តភាពរវាងមនុស្សផងគ្នាឲ្យជាប់មាំមួន មិនមានចំណងអ្វីវិសេសក្រៅពីចំណងគឺទាននេះទេ ដូចពុទ្ធភាសិតថា “ទទំ មិត្តានិ គន្ថតិ បុគ្គលអ្នកឲ្យទានរមែងចងមិត្តភាពបាន” ។ ការឲ្យទានឈ្មោះថាផ្ចាលផ្ចាញនូវសត្រូវគឺសេចក្តីកំណាញ់ ។ សេចក្តីកំណាញ់ជាមន្ទិលមួយយ៉ាងធំ ជាឧបសគ្គរាំងរាមិនឲ្យបានប្រយោជន៍ក្នុងលោកទាំងពីរ គឺលោកនេះនឹងលោកខាងមុខ ។ ទានក្នុងព្រះពុទ្ធសាសនាមានច្រើនយ៉ាងណាស់ តែបើរួមឲ្យខ្លីមកនៅត្រឹមតែ ២ យ៉ាងគឺ បាដិបុគ្គលិកទាន ១ សង្ឃគតទាន ១ ។ ទានដែលបុគ្គលឲ្យចំពោះបុគ្គលម្នាក់ៗ ហៅថា បាដិបុគ្គលិកទាន ។ ទានដែលបុគ្គលឲ្យចំពោះសង្ឃ គឺបុគ្គលជាពួកជាក្រុម ហៅថា សង្ឃគតទាន ។ បាដិបុគ្គលិកទាន ហៅថា អសាធារណទាន ប្រែថា ទានមិនទូទៅដូចេះវិញក៏បាន ព្រោះជាទាន

ដែលគេឲ្យចំពោះរូបបុគ្គលម្នាក់ៗ មិនទូទៅដល់អ្នកឯទៀត ៗ ឯសង្ឃ-គតទាន ហៅថា សាធារណទាន ប្រែថា ទានទូទៅ ដូច្នេះវិញក៏បាន ព្រោះជាទានដែលគេឲ្យមិនចំពោះរូបបុគ្គលម្នាក់ៗ គឺឲ្យទូទៅទាំងអស់មិនថាបព្វជិតឬគ្រហស្ថ, មនុស្សឬសត្វ ៗ មាតាបិតា ថែទាំរក្សាចិញ្ចឹមបីបាច់បុត្រធីតា ដោយការឲ្យអាហារបាយទឹកនំចំណីគ្រឿងស្លៀកពាក់មានសំពត់អាវសាវស្បៃជាដើម ឬឲ្យទីលំនៅផ្ទះសំបែងទ្រព្យសម្បត្តិមាសប្រាក់កែវកងដល់បុត្រធីតា, គ្រូអាចារ្យ ឲ្យចង្ហាន់បិណ្ឌបាត្រសំពត់ចីវរឬបរិក្ខារផ្សេងៗ ដល់សិស្សគណរបស់ខ្លួន, ស្វាមីឲ្យគ្រឿងអលង្ការ, គ្រឿងស្អិតស្អាងខ្លួនប្រាណដល់ភរិយារបស់ខ្លួន, មិត្រសម្លាញ់ឲ្យរបស់នេះនោះដល់មិត្រសម្លាញ់ផងគ្នា, ចៅហ្វាយនាយឲ្យកោតសម្ព័ទឬយសសក្តិតំណែងមុខក្រសួងណាមួយដល់កម្មករ ៗ ឯបុត្រធីតា, សិស្ស-គណ, ប្រពន្ធ, មិត្រសម្លាញ់និងកម្មករដែលបានទទួលនូវការសង្គ្រោះទំនុកបំរុងយ៉ាងនេះហើយ ធ្វើបដិការតបស្នងលោកទាំងនោះវិញ យ៉ាងនេះហៅថា បាដិបុគ្គលិកទាន ឬអសាធារណទាន ព្រោះបុគ្គលឲ្យទានឬបូជាតបស្នងសងគុណចំពោះរូបបុគ្គលម្នាក់ៗ ។ សេចក្តីសប្បាយរីករាយដែលកើតឡើងពីទ្រព្យសម្បត្តិយសសក្តិ និងមានមេត្រីអំពីឯកជននេះ មិនអាចឲ្យសម្រេចប្រយោជន៍និងសេចក្តីសុខដ៏ទូលំទូលាយបានឡើយ ព្រោះថាមនុស្សម្នាក់នឹងរស់នៅយូរប៉ុន្មាន, ទ្រព្យសម្បត្តិក៏

យសសក្តិក្តី មេត្រីសេចក្តីរាប់អានក្តី ដែលឯកជនស្វែងរកបានមកនោះ រមែងសម្រេចប្រយោជន៍ចំពោះតែខ្លួនមួយប៉ុណ្ណោះ មិនអាចសម្រេចប្រយោជន៍ដល់ជនដទៃទៅបានឡើយ ។ ការសង្គ្រោះស្រោចស្រង់ចំពោះបុត្រធីតា របស់មាតាបិតា, ចំពោះសិស្សគណ របស់គ្រូអាចារ្យជាដើមនោះ ឈ្មោះថាបានសម្រេចប្រយោជន៍នឹងសេចក្តីសុខដែរហើយ ក៏ប៉ុន្តែនៅមិនទាន់ធំទូលាយនៅឡើយ ព្រោះថាបើប្រៀបធៀបនឹងសេចក្តីសុខរបស់ជនរួមជាតិ ក៏នឹងឃើញប្រាកដថាជាសេចក្តីសុខ នៅតូចតិចនៅឡើយ ។ ព្រោះហេតុនោះ ការឲ្យមានជាសាធារណប្រយោជន៍ដល់ជនរួមជាតិ ទើបឈ្មោះថាបានសេចក្តីសុខយ៉ាងប្រសើរ គ្រាន់បើជាងសេចក្តីសុខក្នុងគ្រួសារ ឬក្នុងត្រកូលមួយៗ ។ ឯការឲ្យមានជាសាធារណប្រយោជន៍ដល់មហាជនក្នុងលោកទាំងមូល រឹងរឹតតែបានសេចក្តីសុខធំទូលំទូលាយជាកិយ្យាភាពទៅទៀត ។ ព្រោះសេចក្តីសុខដែលមនុស្សច្រើនគ្នាត្រូវបាន ដោយសារអំណាយរបស់ខ្លួន ជាសុខធំទូលាយ ។ ហេតុនេះ គួរឃើញប្រយោជន៍នឹងសេចក្តីសុខរបស់ពួកមនុស្សភាគច្រើនថាជាធម្មជាតធំ ឬប្រសើរជាងប្រយោជន៍ផ្ទាល់ខ្លួន ហើយត្រូវលះបង់ប្រយោជន៍ផ្ទាល់ខ្លួន សេចក្តីសុខផ្ទាល់ខ្លួន ដើម្បីប្រយោជន៍នឹងសេចក្តីសុខដល់មនុស្សភាគច្រើន ។ ក៏ការលះបង់ប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីពួកមនុស្សភាគ ច្រើននោះ បើពោលដោយចំពោះ

កគឺការលះទ្រព្យសម្បត្តិរបស់ខ្លួនទំនុកបំរុងដល់មនុស្សទូទៅមិនរើសមុខៗ ការឲ្យទានជាសាធារណ៍ មិនចំពោះរូបបុគ្គលម្នាក់ៗ យ៉ាងនេះ ហៅថា សង្ឃគតទាន ឬ សាធារណទាន ។ ទានដែលបានផលទាំងថ្ងៃទាំងយប់ មិនមានចន្លោះលស់ខាន ហើយបានសេចក្តីចំរើនរុងរឿងក្នុងបច្ចុប្បន្ន ទានក្នុងនោះគឺ ការសង់ស្ពានសម្រាប់ឆ្លង ព្រែក ស្ទឹង បឹង ទន្លេ, សង់ផ្លូវថ្នល់សម្រាប់ត្រាច់ចរទៅមកកាន់ស្រុកតូចធំនិគមជនបទផ្សេងៗ, សង់សាលារៀន ដើម្បីទំនុកបំរុងបំណេះវិជ្ជា ដល់កុមារកុមារី, សង់មន្ទីរពេទ្យសម្រាប់ព្យាបាលរោគសាធារណជន ឬចែកថ្នាំរោគដល់សាធារណជន, ជីកស្រះ ជីកអណ្តូង ជីកព្រែក ឲ្យមានទឹកដល់សាធារណជន ដាំដើមឈើមានម្លប់ត្រឈឹងត្រឈៃ មានផ្លែផ្កាជាក់ជាទានក្នុងប្រទេស, សង់នូវទីសំណាក់ភាក់ភាស្រ័យ សម្រាប់មហាជនទៅមកជ្រកកោនការពារសេចក្តីសុខ ។ ការលះបង់ទ្រព្យរបស់ខ្លួនទំនុកបំរុងសាធារណជនមិនរើសមុខ ដោយអធ្យាស្រ័យប្រកបដោយមេត្តាយ៉ាងនេះ ឈ្មោះថាលះបង់សេចក្តីសុខផ្ទាល់ខ្លួន ដូរយកសេចក្តីសុខយ៉ាងធំទូលំទូលាយ ។ អ្នកប្រាជ្ញពីបុរាណ បាននិទានរឿងសេដ្ឋីចិត្តសប្បុរសឈ្មោះអនាថបិណ្ឌិក ដែលសង់រោងទាន ចែកអាហារបាយទឹកនំចំណីដល់អ្នកក្រីក្រកំសត់ទុគ៌តជាដើមជាតួយ៉ាង ។ ប្រទេសខ្មែរយើង, ប្រសិនបើយើងប្រមូលគ្នាសាងផ្លូវថ្នល់គមនាគមន៍ សង់ស្ពាន សាលារៀន

សាលាសំណាក់ ជីកស្រះជីកអណ្តូងទឹក សាងមន្ទីរពេទ្យ ទំនុកបំរុងការព្យាបាលរោគគ្រប់តែទីកន្លែង នោះសមនឹងបានសេចក្តីថ្កើងរុងរឿងសប្បាយណាស់ ។ ការឲ្យទានដោយសេចក្តីសង្គ្រោះ ឬដោយមេត្តាចិត្ត ចំពោះសាធារណជនមិនរើសមុខយ៉ាងនេះ ចាត់ជាបារមីមួយយ៉ាងហៅថា ទានបារមី ជាបារមីដែលព្រះពុទ្ធជាម្ចាស់បានបំពេញច្រើនជាតិជាអនេកមកហើយ ។ អ្នកប្រាជ្ញពីបុរាណបានសំដែងរឿងព្រះបរម-ពោធិសត្វព្រះនាមព្រះបាទស្រីវេស្សន្តរជាតួយ៉ាង ដែលទ្រង់បំពេញទានបារមី គឺឲ្យទានយ៉ាងធំហៅថា សតសត្តកមហាទាន ដល់ស្មូមយាចកអ្នកក្រីក្រគោកយ៉ាក ហើយលះបុត្រធីតានឹងភរិយា រហូតដល់សរីរយរាងកាយរបស់ព្រះអង្គឲ្យជាទានថែមទៀត ដើម្បីប្តូរយកប្រាជ្ញាពោធិញ្ញាណ ។ ម្យ៉ាងទៀត, ការឲ្យទានជាសាធារណប្រយោជន៍មិនរើសមុខ លោកទុកថាជាមេបុណ្យយ៉ាងឧត្តុង្គឧត្តម ព្រោះបានបុណ្យទាំងយប់ទាំងថ្ងៃពិតប្រាកដឥតសង្ស័យឡើយ, បើមហាជនចូលទៅប្រើប្រាស់មេបុណ្យយើងពេលណា យើងបានបុណ្យពេលនោះ ទេពតាក៏រក្សាយើងឲ្យបានសុខ ហើយលុះទំលាយកាយអំពីលោកនេះទៅ យើងមុខជានឹងទៅកើតក្នុងស្ថានសួគ៌ ដោយទិព្វសម្បត្តិក្នុងទេវលោក សមដូចជាពុទ្ធភាសិតក្នុងវនរោបសូត្រគម្ពីរសំយុត្តនិកាយ សគាថវគ្គថា:

អារាមរោបា វនរោបា យេ ជនា សេតុការកា
បបញ្ច ឧទបានញ្ច យេ ទទន្តិ ឧបស្សយំ
តេសំ ទិវា ច រត្តោ ច សទា បុញ្ញំ បវឌ្ឍតិ
ធម្មដ្ឋា សីលសម្បន្នា តេ ជនា សគ្គគាមិនោ ។

“ជនណាដាំដើមឈើមានផ្លែផ្កា ដាំដើមឈើមានម្លប់ត្រឈឹង ត្រឈៃ សង់ស្ពាន សង់សាលារៀន ជីកស្រះជីកអណ្ដូងឲ្យមានទឹក ឲ្យនូវទីសំណាក់គាក់អាស្រ័យ, បុណ្យរមែងចំរើនទាំងថ្ងៃទាំងយប់គ្រប់ពេលវេលាដល់ជនទាំងឡាយនោះ; ជនទាំងនោះឈ្មោះថាតាំងនៅក្នុងធម៌ បរិបូរដោយសីលហើយ មុខជានឹងបានទៅកើតក្នុងស្ថានសួគ៌ជាប្រាកដ” ។

ការឲ្យទានជាសាធារណប្រយោជន៍ មិនរើសមុខដូចបានអធិប្បាយមកនេះ ឈ្មោះថាសង្គហធម៌ទី ១ សម្រាប់យឹតយោងស្រោចស្រង់ ឬ ទាញចិត្តនរជនទូទៅឲ្យមានសាមគ្គីរបរមគ្គាជាធ្ងន់មួយ នឹងជាឧបាយនាំឲ្យបាននូវសេចក្ដីសុខក្នុងលោកនេះនឹងលោកខាងមុខ ។

២— បិយវាចា:- ការពោលពាក្យគួរឲ្យចង់ឮ ឬ ចង់ស្ដាប់ ឬពោលពាក្យពីរោះគួរជាទីពេញចិត្ត ហៅថា បិយវាចា ។ បិយវាចានេះ ជាគុណជាតអាចទាញចិត្តមនុស្សក្នុងលោកឲ្យស្រឡាញ់រាប់អានគ្នា ឲ្យមូល

មិត្រគ្នាបាន សូម្បីមនុស្សដែលពីដើមធ្លាប់ទាស់ទែងខ្វែងគំនិតគ្នាក៏ដោយ កាលបើបានឮបានស្ដាប់នូវពាក្យពីរោះផ្អែមល្ហែម គួរឲ្យចង់ឮចង់ស្ដាប់ គួរជាទីពាប់ចិត្តហើយ គង់នឹងអាចរំលស់កំហឹងនឹងការទាស់ទែងខ្វែងគំនិតគ្នានោះឲ្យរលស់ស្រកស្រុតទៅបាន ។ ធម្មតាអ្នកឲ្យទាន បើគ្រាន់តែមានសទ្ធាចេះតែឲ្យៗ ប៉ុណ្ណោះ មិនចេះនិយាយពាក្យពីរោះពីសាគួរពាប់ចិត្តផងទេ នោះសូម្បីទេយ្យវត្ថុច្រើនអំពាសយ៉ាងណាក៏ដោយ ក៏ប្រាកដដូចជាតិចតួចទៅវិញ បើពោលនូវពាក្យពីរោះសុភាពទន់ភ្លន់ គួរឲ្យពេញចិត្តថែមទៀត នោះទេយ្យវត្ថុសូម្បីតិចតួច ក៏ប្រាកដដូចជាច្រើនពោរពាស ព្រោះពាក្យពីរោះនោះឯងអាចប្រមូលមហាជន ឲ្យមានសេចក្ដីស្រឡាញ់រាប់អានគ្នារឹតតែខ្លាំងឡើងទៀត ។ ឯការពោលពាក្យពីរោះគួរពេញចិត្តនេះ បានខាងការវៀរតមនូវការពោលពាក្យទ្រគោះបោះបោករម៉ាំងរម៉ោកគំហកគំហើនខ្ទោះខ្ទរមិនគួរស្ដាប់ ឬពាក្យដេរប្រទេចផ្ដាសាប៉ងប្រាថ្នានឹងឲ្យអ្នកដទៃអ័ប្បយសសក្ដិ ធ្វើឲ្យអ្នកដទៃប្រែឡូតខេវខឹងនឹងសំដីខ្លួន ។ កថាល្អ, សំដីពីរោះជាសំដីកាត់ថ្លៃមិនបាន ជាសំដីមានខ្លឹមសារលើសលែងវត្ថុទាំងអស់ ។ បិយវជ្ជៈ ដែលប្រែថាសំដីពីរោះគួរពាប់ចិត្តនេះចែកជា ២ យ៉ាង គឺ :

១ — បិយវាចា សំដីពីរោះផ្អែមល្ហែម ញ៉ាំងអ្នកស្ដាប់ឲ្យចូលចិត្តចង់ស្ដាប់;

(មានត)

អក្សរសាស្ត្រជាពន្លឺជាតិ ជាគោលបវរកជាតិ
អក្សរសាស្ត្ររលត់ ជាតិរលត់ ។

# ប្រវត្តិសម្តេចព្រះសុគន្ធាធិបតី ប៉ាន

# សង្ឃនាយកគណៈធម្មយុត្តិ

( ដកស្រង់ចាកច្បាប់វិន័យវណ្ណនា )

សម្តេចព្រះសុគន្ធាធិបតី ប៉ាន សម្ភពនៅថ្ងៃ ៥ ᧡ ១២ ឆ្នាំចអដ្ឋស័ក ចុ.ស. ១១៨៦ ព.ស. ២៣៨៧ នៅភូមិព្រែកព្រះស្តេច ខេត្តបាត់ដំបង ។ ឯស្រុកកំណើតមាតាបិតានៅភូមិស្មោង ស្រុកស្មោង ខេត្តកំពង់ធំ, តែបានជាឃ្លាតទៅនៅបាត់ដំបងនោះ ដោយហេតុស្រុកទេសកើតចលាចលក្តីប្រែព្រោះគេដោទែន ។

កាលព្រះជន្មបាន ១២ ឆ្នាំ បានបួសជាសាមណេរនៅវត្តពោធិ៍ ស្រុកសង្កែ បាត់ដំបង បានមួយវស្សា ក៏បានចូលទៅនៅវត្តសកេត ក្រុងទេព ( ប្រទេសថៃ ) ដើម្បីសិក្សាព្រះត្រៃបិដក ។

ព្រះជន្ម ២១ ឆ្នាំ បានឧបសម្បទជាភិក្ខុក្នុងគណៈមហានិកាយ បាន៤វស្សា ។ ដល់ថ្ងៃ ᧡ ៨ ឆ្នាំរកានព្វស័ក ចុ.ស. ១១៩៩ ព.ស. ២៣៩១ បានចូលឧបសម្បទក្នុងសំណាក់សម្តេចព្រះបមក្សាវ ។ ជាព្រះឧបជ្ឈាយ៍ ចៅឃុនព្រះញាណរក្ខិត ( សុត ) ជាកម្មវាចាចារ្យ, ព្រះអមរាភិរក្ខិត ( កើត ) ជាអនុសាវនាចារ្យ, នាមឆាយា បញ្ញាសីលោ

គង់នៅវត្តបរមនិវាស ។ បានប្រឡងដេញប្រយោគចំណោះភាសាបាលី នៅវត្តព្រះកែវហ្វូនជាប់បាន ៤ ប្រយោគ ហើយបានឡើងសមណស័ក្តិ ជាមហាទ្រង់គ្រឿង បាននិច្ចភត្ត ៤៨ បាទ ក្នុងមួយឆ្នាំ ។

ដល់មកឆ្នាំខាលឆស័ក ចុ.ស. ១២១៦ ព.ស. ២៣៩៧ មានព្រះរាជសុភអក្សរនៃព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី (ព្រះអង្គ-ឌួង) ព្រះចៅក្រុងកម្ពុជាឲ្យទៅសុំវង្សធម្មយុត្តមកនៅប្រទេសកម្ពុជា, ទើបសម្តេចព្រះចមក្លាវទ្រង់ព្រះរាជានុញ្ញាតហើយ បានថ្វាយគម្ពីរ ៨០ ឲ្យទៅឃុន អមរាភិរក្ខិត (ជួន), ព្រះមហា (ប៉ាន), ព្រះសង្ឃ ៦ អង្គ នឹងឧបាសក ២ នាក់ ចេញមកប្រទេសខ្មែរ គង់នៅវត្តសាលាគូ (វត្តអម្ពិលប៊ី) ឧត្តុង្គមានជ័យ, ផ្សាយធម៌វិន័យពុទ្ធសាសនាដល់បរិស័ទទាំងឡាយ ។

## សមណស័ក្តិ:

១ – ព្រះអរិយវង្ស

២ – ព្រះវិមលធម្ម

៣ – ព្រះមហាវិមលធម្ម

៤ – សម្តេចព្រះសុគន្ធាធិបតីសង្ឃនាយក ។

ដល់ចុ.ស. ១២២៧ ឆ្នាំឆ្លូវសប្តស័ក ព្រះបាទសម្តេចព្រះនរោត្តម (ព្រះសុវណ្ណកោដ្ឋ) ព្រះចៅក្រុងកម្ពុជា ស្តេចមកតាំងក្រុងនៅភ្នំពេញ បានសាងវត្តបទុមវតីប្រគេនសម្តេចព្រះសុគន្ធាធិបតី (ប៉ាន) គង់រៀងមកៗ

សម្តេចបានសូមព្រះរាជានុញ្ញាតចាត់ព្រះសិរីកជេនធម្ម (ចាប) នឹងព្រះសង្ឃ ៤ អង្គ ជាសាសនទូតឲ្យនាំគ្រឿងសក្ការៈទៅលង្កាទ្វីបដើម្បីផ្សៀងពុទ្ធសាសនា ។ កាលនោះព្រះមហាសុភូតិមហាថេរពមាញ្ញាវង្ស នៅលង្កាទ្វីប បានចាត់ឲ្យព្រះសង្ឃត្រូវព្រះនាមរតនសារៈ អញ្ជើញសក្ការៈតបវិញគឺព្រះបរមសារីរិកធាតុ ១ ព្រះអង្គនឹងព្រះអរហន្តធាតុ ១ អង្គ ព្រមទាំងកូនព្រះពោធិព្រឹក្ស ១ ដើមផង ។ កូនព្រះពោធិព្រឹក្សនេះ សម្តេចបានឲ្យដាំនៅមុខវត្តបទុមវតីនៅថ្ងៃ ៣ ៗ ១០ ៣ ឆ្នាំកុរនព្វស័ក ព.ស. ២៤៣០ (គ.ស. ១៨៨៧) ។ បំណែកព្រះបរមសារីរិកធាតុ សម្តេចកំពុងប្រារព្ធឲ្យសាងព្រះចេតិយដើម្បីដំកល់, ក៏ស្រាប់តែចាប់មានប្រឈួនបុកសៀតព្រះឧទរ ហើយសុគតដោយរោគនេះ នៅថ្ងៃ ៧ ៗ ៨ ៣ ឆ្នាំម្សាញ់បញ្ចស័ក ព.ស. ២៤៣៦ (គ.ស. ១៨៩៤) ក្នុងព្រះជន្មគំរប់ ៦៨ ឆ្នាំ, ព្រះវស្សាបាន ៤៨ វស្សា ។

បំណេះវិជ្ជានៃសម្តេចព្រះសុគន្ធាធិបតី គឺ ភាសា-អក្សរសំស្ក្រឹត, មគធៈ, សៀម, លាវ, ភូមា, មន, លង្កា ។

សម្តេចបានរៀបរៀងអភិធានប្បទីបិកា, អត្ថាភិធានស័ព្ទ, អត្ថមុត្តិស័ព្ទ, ព្រះរាជស័ព្ទ, បុព្វសិក្ខា, វិនយវណ្ណនា, អគារិយវិន័យ ព្រមទាំងបានពន្យល់អក្សរ-ភាសាខ្មែរបុរាណឲ្យលោកអៃមូញេ ៗ បានកត់ត្រាចុះសៀវភៅបោះពុម្ពក្នុងក្រុងប៉ារីសសព្វថ្ងៃនេះផង ។

ប៊ូ-ប៉ូរ

ការកសាងខ្លួនដើម្បីទទួលនូវសេចក្ដីសុខ

យើងជាអ្នកកាន់ព្រះពុទ្ធសាសនា យើងបានដឹងដោយច្បាស់លាស់ថា ខ្លួនប្រព្រឹត្តយ៉ាងណា តែងបានផលមកយ៉ាងនោះ គឺ យើងជាអ្នកកសាងជោគវាស្នារបស់ខ្លួនយើង ពុំមាននរណាប្រសិទ្ធិឲ្យទេ, សូម្បីបើដូច្នេះគង់យើងនៅជាអ្នកដែលសំណាងមិនចូលមកសង្គ្រោះឲ្យសមដូចចិត្តគិតសោះ គេចូលនឹកថាសំណាងនោះនៅក្នុងកណ្ដាប់ដៃយើងរាល់គ្នា តែយើងមិនបេះរក មិនបេះប្រើ មិនបណ្ដុះបណ្ដាលឲ្យលូតលាស់ជាប្រយោជន៍ដល់យើង បើដូច្នេះតើ យើងត្រូវបន្ទោសនរណា ? ។

យើងត្រូវដឹងថា ក្នុងខ្លួនយើងមួយរូបៗ តែងមានមូលធនដែលយើងមិនស្គាល់គឺសមត្ថភាពខាងកាយនឹងខាងចិត្ត សមល្មមនឹងផ្ដល់នូវសុខភាពផលសំរេចនឹងសេចក្ដីសុខឲ្យយើងបាន, តែយើងបែរជាបណ្ដោយទុកឲ្យដេកស្ងៀមអសារឥតការទៅវិញ ។ បើយើងប្រឹងប្រែងបណ្ដុះបណ្ដាលនូវសមត្ថភាពទាំងនោះឡើង មុខជានឹងបានចំរើនជាងសព្វថ្ងៃ ១ ជា ១០ ពុំខាន, ពូជទាំងនោះបំរុងតែឲ្យផ្កា គោងយើងយកទៅដាំលើដីដ៏មានជីជាតិ ។ សម័យនេះជាសម័យដែលយើងរាល់គ្នាគប្បីតែកសាងខ្លួនយើងដោយមធ្យ័ត កសាងខ្លួនឲ្យបានជាអ្នកថ្លៃថ្នូរ ជាអ្នកមានជោគវាស្នាល្អ ។ លោកវិចទ័រហ៊ូស៊្ហូគ៍បានពោលថា "អ្នកមានកេតព្យាធិគ្មានសំណាង ព្រោយលំបាកឬ? ទាំងនេះមកពីអ្នកមិនយល់ពីជីវិតខាង

កាយនឹងខាងសីលធម៌របស់អ្នកដោយច្បាស់លាស់ ៗ តែប្រែជីវភាពរបស់អ្នកទៅ! ចូរអ្នកបង្ខំខ្លួនអ្នក ដើម្បីកសាងកាយនឹងចិត្តរបស់អ្នកឲ្យពេញលេញបរិបូណ៌!" ៗ

ដើម្បីញ៉ាំងបំណងនេះឲ្យបានសំរេច ខ្ញុំសូមរួបរួមសេចក្ដីពន្យល់ពីការកសាងខ្លួនតាមគំរូផ្សេងៗ ទុកជូនដូចតទៅ ៗ

## សុខភាពជាលក្ខណៈសម្បត្តិនៃសេចក្ដីសុខ

ជីវិតមនុស្សជាការតស៊ូជានិច្ច រវាងកំឡាំងរបស់យើងនឹងកំឡាំងខាងក្រៅ មានកំឡាំងធម្មជាតិ កំឡាំងលោកធាតុ កំឡាំងហេតុភេទផ្សេងៗជាដើម ហើយក្នុងការតស៊ូនោះ បើកំឡាំងយើងមានជ័យជំនះ យើងក៏មានក័ព្វបានគប់ប្រសព្វនឹងសេចក្ដីសុខ, តែបើកំឡាំងយើងទន់ខ្សោយ យើងធ្លាក់ខ្លួនជាចំណែកចាញ់ យើងនឹងទទួលនូវទុក្ខវេទនាជាអនេកប្បការ ៗ តែយើងត្រូវការប្រាថ្នាសេចក្ដីសុខគ្រប់រូប, ដូច្នេះគោងយើងប្រឹងយកឈ្នះជានិច្ច ឈ្នះហើយគោងឈ្នះទៀត រហូតដល់បានឈ្នះជាការដាច់ស្រេច ៗ

ដែលនឹងឈ្នះបាន គោងទ្រទ្រង់កំឡាំងក្នុងខ្លួនៈយើងឲ្យខែងរែងឥតអាក់ ៗ កំឡាំងទាំងនោះ ពិតមែនជាមាននៅជានិច្ចប្រចាំរូប តែកាលបើយើងមិនបានខំចំរើនហ្វឹកហ្វឺនរៀនពល់ថែទេ គង់នឹងប្រែក្លាយជាសភាវៈសាបរលាបម្រើការមិនកើត ដូចជុំថ្មពេជ្រដែលនៅតាំងកំពេល

បើគេមិនយកមកប្តូរបន្ទាឲ្យព្រោយបន្ទីចាំងរស្មីទេ នឹងប្រែក្លាយជារបស់មានដំឡើងពុំបាន ។ ចំហាយទឹកដែលហុយឯង ៗ ឥតបទ សូម្បីច្រើនយ៉ាងណា ក៏មិនអាចនឹងចំរើនថាមពលជាប្រយោជន៍ដល់មនុស្សបានឡើយ តែបើគេគ្រប់គ្រងចំហាយនោះទុកដោយល្អ ថែក្ដើងឲ្យឆេះបរិបូណ៌ ចំហាយនោះត្រឡប់ជាផ្ទុកនូវថាមពលយ៉ាងខ្លាំង ប្រើការឲ្យបង្វិលយន្តបុបក្រកបាន សេចក្ដីនេះយ៉ាងណាមិញ កំឡាំងក្នុងខ្លួនយើងក៏យ៉ាងនោះដែរ ។

ឯកម្លាំងនោះមាន ៣ ប្រការ គឺកម្លាំងកាយ កម្លាំងចិត្ត កម្លាំងបញ្ញា; បណ្ដាកម្លាំងទាំង ៣ អ្នកប្រាជ្ញចិត្តសាស្ត្រមូលមតិថាត្រូវចំរើនកម្លាំងកាយជាមុន ព្រោះរាងកាយជាឧបករណ៍សំខាន់របស់ចិត្ត "ចូរចំរើនកម្លាំងកាយឲ្យបរិបូណ៌ ដើម្បីទ្រទ្រង់នូវកម្លាំងចិត្ត" នេះជាភាសិតរបស់លោក រូវ៉ឺណាក៌ ។ តាមដែលបានសង្កេតមកឃើញថា កម្លាំងក្នុងខ្លួនរបស់យើងតែងប្រព្រឹត្តទៅតាមសភាពសរីរកាយនឹងសរីរយន្តរបស់យើងជាធម្មតា ។ កាលរាងកាយមិនសប្បាយ ចិត្តគំនិតរបស់យើង មិនថ្លាស្រឡះកើតហ្មងហ្មៅស្ងប់ស្ងលអាប់បញ្ញាស្មារតី គិតការអ្វីៗ ពុំសំរេច នាំឲ្យខ្ជិល ឲ្យរសាយដៃ ឲ្យធូរសេចក្ដីព្យាយាម តែបើចិត្តគំនិតមិនស្រស់ស្រាយ រាងកាយគង់ប្រែសភាពទៅតាមគ្នា ដូច្នេះរាងកាយនឹងចិត្តគំនិតមានការទាក់ទងគ្នាយ៉ាងស្និទ្ធ ហើយមានសេចក្ដីត្រូវការដូចគ្នា ។

សូមលើកឧទាហរណ៍មួយមកជួយបញ្ជាក់ ចិត្តគំនិតរបស់យើងតែងប្រព្រឹត្តទៅតាមសេចក្ដីស្ដីការ ត្រួតត្រា បង្គាប់បញ្ជា របស់ខួរក្បាល ខួរក្បាលដើរបានល្អ លុះតែរងថ្វា ស្រោចស្រប់ដោយឈាមស្អាត ប្រាសចាកជាតិពុលជានិច្ច ឈាមនឹងស្អាតបាន ព្រោះការចំរើនកម្លាំងរាងកាយតាមរបៀបហ្វឹកហាត់នឹងច្បាប់អនាម័យ ។

គង់កើតពាក្យសឹកសៀតថា ចុះបើសេចក្ដីសុខនិងទុក្ខប្រាកដមានឡើងព្រោះចិត្តទេ ចាំបាច់ថែរក្សារាងកាយឲ្យខាតពេលធ្វើអ្វី គិតតែប្រដៅចិត្តប៉ុណ្ណោះបានហើយ ។ មែនពិត យើងបានសុខឬទុក្ខព្រោះចិត្ត តែសេចក្ដីនេះមិនមែនបង្គាប់ឲ្យយើងធ្វេសប្រហែសមិនរវល់ដល់រាងកាយឡើយ ព្រោះចិត្តយើងដែលនឹងមានកំឡាំងខែងរ៉ែងបាន អាស្រ័យដល់ថាមពលរបស់រាងកាយ ថាមពលនេះនឹងមានបរិបូណ៌គ្រប់គ្រាន់ព្រោះរាងកាយខែងរ៉ែង ។ ចិត្តមានអំណាចសង្កត់រាងកាយមែន តើចិត្តនោះយើងបានដុសខាត់ល្អគ្រប់គ្រាន់ហើយឬនៅ? មួយវិញទៀត បើនឹងប្រឹងខាងចិត្តត្រួតកាយខ្លាំងពេកទៅ ថាមពលក៏ទន់ខ្សោយមិនឲ្យប្រយោជន៍តាមសេចក្ដីប្រាថ្នា ដោយអាការម្នាម្នះនៃរាងកាយនោះឯង ហើយបើរវល់តែនឹងគ្រប់គ្រងរាងកាយ ដែលទ្រុឌទ្រោមដោយការមិនថែរក្សានោះ ចិត្តនឹងមានអានុភាពតាំងច្បាំងនឹងអំណាចខាងក្រៅបានប៉ុន្មាន? ឯការមានសុខភាពបរិបូណ៌លោកចាត់ជាលាភដ៏ប្រសើរក្រៃលែង

ដូច្នេះរាងកាយជាលក្ខណសម្បត្តិនៃសេចក្ដីសុខ យើងគួរខំថែរក្សារាង-កាយជាប្រក្រតី ។

បើនឹងយកសេចក្ដីប្រៀបធៀបមកពន្យល់រឿងនេះ មនុស្សយើងដូចកប៉ាល់ រាងកាយជាសំបកកប៉ាល់ ចិត្តដូចគ្រឿងយន្ត ថាមពលដូចកម្លាំងក្ដៅនឹងចំហាយទឹក សូម្បីយើងខំថែគ្រឿងយន្តយ៉ាងណា បើសំបកកប៉ាល់ចាស់គ្រាំគ្រា ក្ដៅពុំមានបរិបូណ៌ កប៉ាល់នោះបើកមិនបានលឿនទេ បើខំដុតក្ដៅក៏គោងប្រើខុសច្រើន ឃើញជាយូរពេលផង ខាតខុសច្រើនផង ហើយបានការតិច ឯគ្រឿងយន្តដែលប្រឹងខ្លាំងគង់ខ្សោយកម្លាំងដោយពិត ។ ឯសេចក្ដីចំរើននោះ គឺ "ត្រូវប្រើកម្លាំងតិចបានការច្រើន" ។

ដោយហេតុនេះ យើងជាអ្នកកសាងជីវិត យើងត្រូវខំចំរើនរាងកាយឲ្យសប្បាយបរិបូណ៌ ដោយប្រតិបត្តិតាមច្បាប់អនាម័យនិងដោយការហាត់ប្រាណ ដើម្បីញុំាងថាមពលឲ្យបំពេញកិច្ចបានពេញលេញ ខួរក្បាលឲ្យថ្លាស្រឡះប្រាសចាកជាតិពុល សំរេចកិច្ចការបានដោយស្រួល តែគោងយល់ថាការចំរើនរាងកាយនេះ ពុំមែនជាវត្ថុបំណងទេ គឺគ្រាន់តែជាមធ្យោបាយសំរាប់ស្វែងរកសេចក្ដីសុខប៉ុណ្ណោះ ព្រោះសុខ-ភាពល្អ នាំឲ្យមានសេចក្ដីក្លាហាន សេចក្ដីទុកចិត្ត សេចក្ដីសង្ឃឹមនិងនាំ

ឲ្យបែកគំនិតគិតការផ្សេងៗ បានធាប់រហ័ស ៗ រួមសេចក្ដីទៅជាឧបករណ៍យ៉ាងសំខាន់សំរាប់ហ្វឹកហ្វឺនចិត្ត ។

សុខភាពមិនល្អមកពី :

១ – អាហារមិនល្អ

២ – ដកដង្ហើមមិនស្រួល

៣ – គេងមិនល្អ

៤ – អនាម័យមិនបរិបូណ៌

អាហារគោជន

អាហារដែលយើងបរិភោគសព្វថ្ងៃ គឺដើម្បីចំរើនកម្លាំងកាយដែលថមថយទៅ ពុំមែនគ្រាន់តែឲ្យរស់ប៉ុណ្ណោះទេ ព្រោះហេតុនោះរឿងអាហារនេះគួរពិនិត្យឲ្យហ្មត់ចត់ ៗ

## ១ – គួរបរិភោគពេលណា

ក – ពេលឃ្លាន ៖– ត្រូវបរិភោគឲ្យមានកំណត់ពេលវេលា កុំដល់ពេលបាយហើយនៅបន្ថែមផ្លែនេះផ្លែនោះជាដាច់ខាត ព្រោះជាទំលាប់ឲ្យខូចខ្លួន នាំឲ្យពុំអាហារមិនឃ្លានមិនឆ្ងាញ់ នឹងឲ្យជាតិពុលជុះក្នុងខ្លួនផង ៗ

បរិភោគ ៣ ដងក្នុង ១ ថ្ងៃល្មមគ្រប់គ្រាន់ហើយ ពេលព្រឹកម្ដងថ្ងៃត្រង់ម្ដង ល្ងាចម្ដង ក្រៅពីពេលនោះ កុំទំលាប់បរិភោគអ្វីឡើយសោះ ៗ

១ – ពេលមិនឃ្លាន.- លុះដល់កំណត់ពេលបរិភោគ ហើយមិនឲ្យឃ្លានបាយ គួរតែមកុំបរិភោគអាហារ ចាំដល់ពេលក្រោយសឹមបរិភោគ ។ កុំមានសេចក្ដីបារម្ភថា ការអត់អាហារនាំឲ្យអត្តភាពទ្រុឌទ្រោមឲ្យ ហោះ មិនដូច្នោះទេ ការអត់អាហារ ជាទុសថវិសេសសំរាប់ឲ្យឆ្ងាញ់បាយឃ្លានអាហារ ជាវិធីរក្សាខ្លួនយ៉ាងស័ក្ដិសិទ្ធិ ជួយទ្រទ្រង់សុខភាពឲ្យបរិបូណ៌ល្អ ដោយទុកឱកាសឲ្យគ្រឿងយន្តសំរាប់រំលាយអាហារ មានពេលសំរាក ។ ពេលអត់អាហារនោះ ត្រូវបរិភោគបន្លែ ស្ងោរទឹកផ្លែឈើមានទឹកក្រូចជាដើម ទឹងផ្លែឈើស្រស់ ។

## ២ – គប្បីបរិភោគអាហារណា ?

មុខអាហារដែលត្រូវបរិភោគមួយពេល ៗ នោះ ទឹងកំណត់ឲ្យដាច់ស្រេចថា ឲ្យជ្រើសបែបណា ៗ នោះពុំបានឡើយ ព្រោះតាងនិយមទៅតាមឋានៈរៀងខ្លួន ក៏ងទីនេះ គ្រាន់តែកយមុខអាហារខ្លះ ៗ ដែលឲ្យគុណឬឲ្យទោសដល់សរីរៈកាយទឹងសរីរៈយន្តប៉ុណ្ណោះ ។

ក – ពេលព្រឹក – ផ្លែឈើស្រស់តាមរដូវកាល ព្រោះក្នុងផ្លែឈើមានជាតិកម្លាំងហៅថា "វីតាមីន" ច្រើន ហើយរើសរកផ្លែឈើទុំយ៉ាងល្អ ៗ ផង សំបកឬគ្រាប់ក្រុតនៃផ្លែឈើនោះគួរពិសាកុំចោល ព្រោះជាជំនួយសំខាន់ដល់ការផ្ចាញ់ផ្ចាលរោគគ្រៀនលាមក ។ ត្រូវប្រើផ្លែឈើស្រស់ជា

បន្ថែមណាស់មាត់ គ្រប់ពេលអាហារ ។ បើចង់បរិភោគអាហារពេលព្រឹក គោង់ធ្វើកាយកម្មជាមុនសិន ។

ខ – ពេលល្ងាច.- បើឆាប់ចូលកាន់ដំណេកត្រូវបរិភោគអាហារទន់ ឯអាហាររឹងទឹងប្រើបានតែពេលដែលនៅដល់អធ្រាត្រ ។

ពេលល្ងាចហាមដាច់មិនឲ្យបរិភោគសាច់ ជ្រើសរើសតែអាហារណាដែលចំរើនកម្លាំងធាតុ ដែលបរិបូណ៌ដោយអំបិលលោហធាតុ ។ បន្លែកុំរំលាស់យូរនាំឲ្យស្លាប់ជាតិវីតាមីន ដល់សម្ពុះល្អហើយសឹមបង់បន្លែរួចលើកចុះពីភ្លើងភ្លាម ។

គ.– ពេលថ្ងៃត្រង់.– បរិភោគឲ្យបរិបូណ៌ ។ អាហារទុកយូរកុំប្រព្រឹត្តញឹកញាប់ពេក ព្រោះគ្មានជាតិកំឡាំងទេ ចំណែកសាច់វិញគួរបរិភោគឲ្យល្មមនឹងទម្ងន់របស់ខ្លួន គឺកន្លះទម្ងន់ ១ គីឡូសាច់ ១ ក្រាមគ្រប់គ្រាន់ហើយ ។

សរុបសេចក្ដីទៅ គួរបរិភោគអាហារធម្មជាតិឲ្យច្រើន គឺបន្លែនឹងផ្លែឈើ នឹងសាច់ឲ្យតែល្មមបានហើយ ។

## ៣.— រឿងភេសជ្ជៈ

ចៀសវាងផឹកទឹកក្នុងពេលអាហារ ព្រោះជាហេតុនាំឲ្យរលាយស្ទើស្ទនឹងទឹកប្រមាត់ ។ កាហ្វេ-តែ-សូកូឡា-ស្រា កុំប្រព្រឹត្តញឹកញាប់ពេក ហើយត្រូវប្រើយ៉ាងតិចបំផុតផង ព្រោះនាំឲ្យភ្លៀនលាមក ។

## ៤.— តោងបរិភោគដូចម្ដេច?

កុំរវល់ពេលអាហារ ធ្វើចិត្តអោយស្រួលឲ្យស្រស់ស្រាយ ប្រ-ស្រ័យរឿងកំសាន្តសប្បាយ ទឹកមុខរីករាយរាក់ទាក់ កុំឈ្លោះប្រកែកគ្នា ធ្វើបែបនេះជាហេតុនាំឲ្យឆ្ងាញ់បាយ ។ ទំពាអាហារឲ្យម៉ដ្ឋ រួចលេបសន្សឹមៗ ឲ្យស្មេស្មុំអាហារល្អ ។ អាហារដែលទំពាល្អហើយ ដូចជារលាយបានពាក់កណ្ដាល ។

## ៥.— វិធីត្រួតពៀងរំលាយអាហារ

បើគ្រឿងយន្តរំលាយអាហាររបស់យើងល្អបរិបូណ៌ ពេលបរិភោគរួច មិននាំឲ្យងឹងងោង ឬឈឺក្បាលវិលមុខ តឹងជួនពោះ ព្រួយចិត្ត ងងុយដេក ឬអន្ទះអន្ទែងមិនស្រួលក្នុងខ្លួនដោយបទឯណានីមួយឡើយ អាចនឹងធ្វើអ្វីក៏បាន តែកុំប្រឹងធ្វើការអ្វីទាំងអស់ ពេលរួចអាហារភ្លាម ពេលល្ងាចតោងដើរកំសាន្តឲ្យរលាយអាហារស្រួលផង ។

បើចង់ពិនិត្យគ្រឿងយន្តរំលាយអាហារ ឲ្យពិសោធមើលដូច្នេះ រួចបាយ ឈរឲ្យត្រង់ខ្នងទៅមុខចុងដៃដល់ដី ហើយងើបឡើងផ្ងារទៅក្រោយវិញ ដោយផតពោះ បើក្នុងពេលនោះមានមិនស្រួលត្រង់ណា ជាសញ្ញាឲ្យដឹងថា ការរំលាយអាហាររបស់យើងនៅមិនទាន់ស្រួលល្អទេ តោងប្រយ័ត្នកែដោយរួសរាន់ ។

## ចំរើនកំឡាំងដកដង្ហើម

អាហារភោជនមានភារៈត្រឹមចិញ្ចឹមសរីរៈរាងកាយប៉ុណ្ណោះ តែជីវិតនឹងប្រព្រឹត្តជាប់តៗគ្នាទៅបាន ដោយអាស្រ័យខ្យល់ដង្ហើមចេញចូល ពេលដែលមិនមានខ្យល់ចេញចូល ជីវិតក៏រលត់ ដែលយើងសន្មតថាស្លាប់នោះឯង ។ រឿងដកដង្ហើម បើមិនពិនិត្យឲ្យហ្មត់ចត់ ក៏យល់ឃើញថាមិនគួរនាំមកនិយាយទេ ព្រោះគេតែងតែដកដង្ហើមជានិច្ចមកហើយ ចាំបាច់រៀនដកដង្ហើមធ្វើអ្វី បើចេះតាំងពីកើតមកម៉្លេះ ។

ដោយពិតនោះ គេតែងទំលាប់បរិភោគអាហារតាមតែបាន យ៉ាងណា គេក៏ទម្លាប់ដកដង្ហើមមិនល្អយ៉ាងនោះដែរ ជាហេតុនាំឲ្យខូចសរសៃប្រសាទនឹងអវយវៈសំខាន់ក្នុងខ្លួនយើងផង ។ ក្នុងសាលារៀនបានសង្កេតជាញឹកញយមកឃើញថា កុមារដែលដកដង្ហើមមិនល្អ មានរាងកាយស្រពោនស្រពាន់ ស្គមកំព្រឹងឃើញតែរាងឆ្អឹង គ្មានស្វាហាប់នឹងរៀនសូត្រឬធ្វើអ្វីក៏ឆាប់ហត់ សម្បុរស្បែកស្លាំង ហើយច្រើនក្អកជានិច្ច ។

### ១ — ប្រយោជន៍នៃការដកដង្ហើម

យើងបានដឹងមកហើយថា ធាតុអុកស៊ីសែន ជាខ្យល់យាងជីវិត ខ្យល់នេះចូលក្នុងខ្លួនយើងបានដោយអាស្រ័យការដកដង្ហើម ដូច្នេះការដកដង្ហើមនេះមានប្រយោជន៍ ដើម្បីចំរើនធាតុអុកស៊ីសែន · ក្នុង

ខ្លួនរបស់យើង ជាតុអុកស៊ីសែនប៉ះនឹងឈាម ធ្វើឈាមនោះឲ្យថ្លាល្អឡើង ផុតបំផ្លាញនូវជាតិពុលនឹងកំទេចអាហារ ដែលចេញមកក្រៅតាមដង្ហើមចេញ ឈាមថ្លារត់ទៅសព្វសរសៃយកជាតុអុកស៊ីសែនទៅចែកចាយគ្រប់អវយវៈ ដើម្បីចំរើនកំឡាំងប្រមូលជាតុខាងក្នុង ដែលទ្រទ្រង់សុខ-ភាពឲ្យសម្បូណ៌ខែងរ៉ែង ពេលដែលដកដង្ហើមចេញចូលនោះ សរសៃពោះ ក៏កន្ត្រាក់ដើរស្រួល ប្រមាត់មានកម្លាំងខែងរ៉ែង ជាជំនួយសំខាន់សំរាប់កិនរំអិតអាហារឲ្យរលាយ កំចាត់ជាតិពុលនឹងកាកអាហារបានស្រួល ជាវិធីកែរោគក្ដៀនលាមកយ៉ាងវិសេស ។

ដូច្នេះ ការហាត់ដកដង្ហើមល្អមានឧបការៈច្រើនក្នុងការញុំាងសេចក្ដីសុខឲ្យប្រាកដដល់រាងកាយ ដែលនឹងដកដង្ហើមបានស្រួលនោះ តោងនៅកណ្ដាលអាកាសល្អ មានអធ្យាស្រ័យស្រស់បស់ ជាអ្នកសុទិដ្ឋិ ជាអ្នកក្រេមក្សាន្ត ហើយបើយើងដកដង្ហើមបានល្អ យើងក៏ប្រកបដោយអធ្យាស្រ័យស្រស់ស្រាយ សុទិដ្ឋិនឹងសេចក្ដីក្រេមក្សាន្ត ព្រោះរាងកាយនឹងចិត្តមានដំណើរទាក់ទងគ្នាជានិច្ច ។

## ២— វិធីហាត់សំរាប់ចំរើនកម្លាំងដង្ហើម

ក— វិធីបោះដៃ.— ឈរឲ្យត្រង់ ដកដង្ហើមសន្សឹមៗ តាមច្រមុះដោយបោះដៃខ្វែងគ្នាទៅក្រោយឲ្យអស់ទំហឹង រួចទប់ដង្ហើមឲ្យនឹងមួយស្របក់

សឹមបញ្ចេញដង្ហើមមកវិញ ដោយទំលាក់ដៃបោះមកមុខ ឬយកមកដាក់លើភ្លៅ ប្រព្រឹត្តបែបនេះបាន ១០ ដងបន្តគ្នា វេលាព្រឹកនិងល្ងាចមុនបរិភោគអាហារ ។

ខ - វិធីរាប់លេខ ៈ— ឈរឲ្យត្រង់ ដកដង្ហើមយ៉ាងវែង រួចទប់ដង្ហើមកុំបញ្ចេញខ្យល់ រាប់កុំឈប់ពី ១ ដល់ ១០ សឹមបញ្ចេញដង្ហើមយ៉ាងវែងសន្សឹមៗ មកវិញ ។

គ – វិធីប្រមាណកម្លាំងទប់ដង្ហើម ៈ— ដកដង្ហើមយ៉ាងខ្លាំងសន្សឹមៗ ទប់ដង្ហើមឲ្យនឹង យកនាឡិកាមកផ្ទៀងមើល គេអាចទប់បានប៉ុន្មានវិនាទី តាមធម្មតាអត់បានពី ២៥ ដល់ ៥០ វិនាទី ហាត់យូរទៅទើបអត់បានចំនួន ១ នាទី ឬច្រើនជាង ១ នាទី បានដោយស្រួល ។ វិធីនេះជាគ្រឿងត្រួតកម្លាំងដង្ហើមផង នរណាទប់បានយូរ អ្នកនោះមានសុខភាពបរិបូណ៌ ឈាមរត់ស្រួល ។

ឃ – វិធីផ្លុំទៀនដុតទៀន ៈ— ដាក់ទៀនពីរពីមុខ មួយឆេះ មួយរលត់ ហាត់ផ្លុំទៀនឆេះ ឲ្យឆ្លងទៅឆេះទៀនរលត់ ហាត់ពីជិតរួចសឹមថយឲ្យឆ្ងាយពីទៀនបន្តិចម្តងៗ ដោយដកដង្ហើមតាមច្រមុះ ផ្លុំតាមមាត់ ពុំនោះហាត់ផ្លុំទៀននេះឲ្យរលត់ក៏បានដែរ ដែលសំខាន់នោះ ត្រង់ចំរើនកម្លាំងដង្ហើមឲ្យខ្លាំងអាចផ្លុំទៀនឲ្យរលត់ពីចម្ងាយបាន បើដង្ហើមដើរស្រួលតាមធម្មតា អាចផ្លុំទៀនឲ្យរលត់បានចម្ងាយ ១ ម៉ែត្រ ។ (មានត)

# ១

## អាស្រមឥសីកាមទេព

### ដំណាលកាលពីព្រឹទ្ធព្រេងនាយ

ព្រៃមួយវែងឆ្ងាយសាយទូលាយ ជាទីរីករាយនៃម្រឹគជាតិ ៗ
មានពោធិ៍មួយដើមសម្បើមក្រៃ សាខាស្កឹមស្កៃគល់បុសព្រោត
ស្លឹកត្រូវខ្យល់បក់ហាក់រនោត ប្រគំពិណពាទ្យពិរោះពេក ៗ
ដើមត្នោតជាជួរជុះរហាង់ ត្រយូងត្រង់ដំរង់ទៅលើមេឃ
កម្ពុទេសប្រួងប្រាងប្រែនអនេក ផ្កលផ្តក់យោលយែកមែកលើគ្នា ៗ
ដោមស្លឹករះញៀវខៀវលេក រដៅទៅមកសព្វវេលា
លន្ទង់លន្ទោចរាយលាតលា កំពូបនានាជាកំពែង ៗ
កំពុំកណ្តាលខ្ពស់ត្រដឹម ត្រដែតសន្ទឹមក្រអឹមដែង
ជួយជ្រោងជួយជ្រុងនៃព្រៃវែង យ៉ាងខែងឯងឯកប្លែកសង្ហា ៗ
ស្លឹងគុម្ពមួយល្អះល្អសោភី ឈ្មោះមលិនីរំថ្ងា
សន្ទ្រមហូរស្វាត់កាត់ព្រឹក្សា សម្បូណ៌មច្ឆាក្ដាលោតលេង ៗ
បុប្ផាជុះហៃក្សែរមាត់ប្រាំង ពិដោរបោលខ្ចាំងក្រអូបឈ្ងុង
ទុនថ្កុះក្មង់ទឹកទទទ់ទន្ទេង ភមររង្វង់វិលត្រឹបត្រង ៗ
ពពកពណ៌មាសព្រៃព្រឹក្សា មេឃខៀវបក្សាផ្ទាហើរខ្ទង

សឹងពោលស្រមោលព្យាសឥតហ្មង ក្នុងទឹកថ្លាខ្យងសត្វអន្ទើ ៗ
ស្រមោលកូនខ្ទមរញមដែក សៀតសឹកដែកជៀតក្រោមដើមឈើ
ផ្ទុះផ្ដិតឥតល្អៀងទៀងទាត់លើ ទឹកឥតរង្គើគួរទស្សនា ៗ
ក្នុងព្រៃសុខុមជុំពួកម្រឹគ មូលមិត្តរីកជាសុខា
រួមតាមដងស្ទឹងខ្ទឹងមនុស្ស ប្រាសចាកបុស្សាចិត្តឃោរឃៅ ៗ
មុជដៃដកមែកឈើស្លឹកលាស់ថ្មី បោលស៊ីស្មៅវីតាមគ្នាទៅ
សត្វក្ដាន់រមាំងកាត់ព្រៃជ្រៅ ល្វាសល្ងន់រាងទៅប្រដេញគ្នា ៗ
ឃើញតែលឿងខ្មៅកាត់ខ្វាត់ខ្វែង ប្រឡូកប្រឡែងតាមពួកវា
លុះហបហត់ហើយឈប់រេក សំពកអង្គាឈរទ្រមឹង ៗ
ខ្លះជ្រៀតស៊ីទៀតយកកំឡាំង ខ្លះស្រេកទឹកខ្លាំងចុះក្នុងស្ទឹង
ផឹកហើយងើបងើយធ្វើសំរឹង បែរក្អែកសំឡឹងមើលនាយអាយ ៗ
ហង្សស្រលេងទ្រង់ពង់ពើងក លៀនលយបន្ដគ្នាប្រញាយ
មាន់ទឹករត់ស្ទៅខ្មៅអន្ទាយ មុជងើបទៅឆ្ងាយចឹកចាប់ត្រី ៗ
បក្សាគ្រប់ពណ៌រន្ទាលផ្ទក ហ្វូងសេកកុះករស្ទាបខៀវខ្ចី
ចំពុះក្រហមចឹកចំណី ដណ្ដើមគ្នាធីលាន់អឺងកង ៗ
សត្វខ្លះហិចហើរឯវេហាស៍ ខ្លះទំទឹមគ្នាដោយស្នេហ៍ស្នង
ខ្លះធ្វើសម្បុកឥតផ្សរផ្សង មូលមីរសាសងប្រិនអនេក ៗ
និទាឃៈកាលសត្វគាប់ យាសយំក្រកៅពិរោះពេក

ព្រលឹមស្រាងៗ ដាស់អ្នកដេក		ឲ្យចាកដំណេកស្រប់ក្ត្រា ។
សារទៈពេលក្សោកកោកក្អើតក្អើន		រហំរពើនបុកសង្ក្រា
ពង់លាកន្ទុយព្រុយសុវណ្ណា		អុតអង្គអាត្មាថាប្រឹមប្រិយ ។
ទៀបគល់ពោធិ៍ចាស់ធំបក្រាំង		នៅរុមទឹងនាងគោតមី
កាមទេពតាបសបួងកេសី		ឃ្នាតខ្វីប្រឹងប្រែងខំស្ទឹងស្នាធ ។
យកសម្បកឈើធ្វើសំពត់		ស្រគត់ស្រគំខំសង្វាត
ហ្វឹកហ្វឺនពត់ចិត្តឲ្យបានស្អាត		ឥតមានប្រមាទធ្វេសសោះឡើយ ។
ព្រះកក្រឹត្យថាផ្លូវផងល្អ		ពុកបង្កាសវៃឯទន់ល្មើយ
ផ្ចញផ្ចាក់កាត់ថ្វាសខ្វះទៅហើយ		មុខគួរត្រាណត្រើយនៃសិស្សគណ ។
កាប់កាច់កូនឈើធ្វើខ្ទមនៅ		ជិតក្រោលគោខ្មៅខិលពេកពន់
កញ្ច្រោលជោលគ្នាឥតគិតគន់		ជោរជន់រកពយផ្កាយដល់ព្រៃ ។
ចំណែកកូនគោពើទគឹកកង		ផ្ទោះផ្ទាតឥតហ្មង់ទៅតាមវ័យ
បោលហត់ប្រែប្រាសបំអែតផ្ទៃ		រួបរៃរំពៃលេងជាថ្មី ។
ឯពួកសិស្សគណមានគំនិត		សង់ខ្ទមនៅជិតតាឥសី
ស្លៀកសម្បកឈើទាំងប្រុសស្រី		មូលមិត្តភក្តិជាធម្មតា ។
កល់ព្រឹករលឹកពីព្រលឹម		ញញឹមប្រឡេះបេះបុប្ផា
យកមកជោតក្រងចងរបនា		ថ្វាត់ថ្វាយទេព្តាទាំងក្នុងក្រៅ ។
រួចនាំគ្នារៀនគម្ពីរវេទ		សង្កេតតាមពាក្យគ្រូប្រដៅ

តាំងចិត្តសិក្សាឲ្យអស់ខ្លៅ លុះថ្ងៃចាំងក្តៅទើបឈប់ខាន ។
នាំគ្នាគគ្រឹកចូលព្រឹក្សា ចរចាសាសងលេងកំសាន្ត
សន្សំមែកឈើថែភ្លើងក្រាន ខ្លះបោសទីឋានឲ្យម៉ត់ហ្មង ។
ខ្លះធ្វៀតឃ្វាលគោឲ្យស៊ីស្មៅ ខ្លះគេចចេញទៅលេងអឹងកង
យកខ្សាច់សង់ផ្ទះស្រាស់របង ស្ទូនដីឥដ្ឋផ្សងធ្វើរូបសត្វ ។
ឬយកស្លឹកពោធិ៍ធ្វើសំពៅ ឲ្យលឿនលយទៅមីរប្រព័ត
លើទឹកស្ទឹងថ្មរខ្យល់បន្សាត់ ដល់ឆ្ងាយលិចបាត់ស្ងាត់ស្ងូន្យសោះ ។
ខ្លះកាត់ឫស្សីធ្វើខ្លុយលេង ផ្លុំភ្លេងរងំគួរស្រណោះ
សត្វផងត្រេកអរចរចូលស្នោះ ស្តាប់ពួកកំឡោះភ្លើនភ្លេចភ្លាំង ។
ពេលល្ងាចពួកសិស្សជុំគ្នា ពណ៌នាទិទានរឿងចំបាំង
យក្សទឹងទេព្តាប្រឹងតតាំង ប្រណាំងតេជដៃយកបេស្កា ។
រួចពលសូត្រធម៌លាន់ខ្ទរខ្ទាយ លាន់លេចពត្រឆ្ងាយសាយព័តា
ជាពាក្យបួងសួងអស់ទេព្តា ឲ្យជួយរក្សាព្រោសប្រណី ។
សែនសុខក្សេមក្សាន្តទាំងឋានបិត ឥតមានវិបរិតពីរឿងអ្វី
ប្លែកតែកាមទេពទឹងគោតមី សោកសៅអស់ក្តីឥតបីស្រាន្ត ។
ព្រោះឃ្លាតអ្វីមួយព្រួយអនេក សង្វេគព្រោះប្រាសទ្រព្យបំណាន
បំណាប់គ្មានអ្វីជំនួសបាន ខ្វាចផ្សារំខានប្រាណស្ងៀមស្ងាត់ ។
ពេជ្រដែលបំភ្លឺទីឆ្ងាយជិត ក្នុងខ្លួនងងឹតវិនាសបាត់

ឥសីរលួយថ្លើមប្រមាត់ ទុក្ខធ្ងន់ពេកក្តាត់ឥតខេត្តខ័ណ្ឌ ។
ពន្លឺជីវិតរលត់ឈឹង ឥតមានទីពឹងទឹងប្រកាន់
បីដូចក្រឹបង់ព្រះចន្ទ្រ អ័ព្ទអួទៅកាន់ទូទិសា ។
ទ្រព្យដ៏ប្រសើរពេជ្រពិសី ប្អូនរស្មីនៃជីវ៉ា
នៃកាយទេពគឺនរណា គឺសក្តុនណាជីតាឆើត ។
ឥសីខ្វក់ខ្វល់ទាសអារម្មណ៍ ប្រឹងដើរចង្ក្រមក៏មិនកើត
ទោះទាំងរនោចទោះទាំងខ្វើត ឥតឆ្អើតអើតកមើលធម្មជាតិ ។
ផ្កានៅមុខខ្ទមទ្រមស្រពោន លំពោនទទន់ទង់តាំងពីឃ្លាត
ពីម្ចាស់ស្រីទៅហាក់អាពាធ ទល់ទុក្ខលែងលាតលារីករាយ ។
កូនប្រើសកំព្រាពសំកុក ស្វល់ស្វប់អផ្សុកចាំចៅហ្វាយ
អង្អែលបីបមថ្នាក់ថ្នមកាយ អ្នកឃ្លាតទៅឆ្ងាយណាយចំណី ។
សត្វសេករវៃរកទំប្រង្វូរ រង់ចាំមើលផ្លូវគល់ព្រៃណី
ក្រែងចេញបែកចាយបាយចំណី បាត់យូរហើរប៉ុអស់ពន្ធឹង ។
ស្ងាត់សូន្យគ្រឹហាវែងសូន្យស្ងាត់ ឈឹងស្ងៀមពេកក្តាត់ស្ងាត់ស្ងៀមឈឹង
វឹងវែងកើតទុក្ខ ទុក្ខវែងវឹង ឃ្លាឃ្លាតព្រលឹងប្រាសឃ្លាតឃ្លា ។
ទៅតាមស្វាមីស្រីតាមទៅ លាចាកលំនៅពៅចាកលា
ពិរះតែឯងតែងរិះពុ ស្ងាត់សូន្យគ្រឹហាវែងសូន្យស្ងាត់ ។

២

# សកុន្តលា

ឯសកុន្តលានារណោះ ទៅហើយនេះសន្តោនៅយូរថ្ងៃ
តាមទេពក្តៅផ្សាដោយអាល័យ នឹងកែខៃប្រម្ដេចក្ដេចពុំបាន ។
គោងសារស័ព្ទប្រាប់សព្ទតាមបំណាំ កាលជប់ប្រាំឆ្នាំមុនកែវកល្យាណ
នាពគ្រីងឹតផិតជុំហាន កើតក្នុងដានព្រឹក្សាស្ងាត់ស្ងួនស្រែង ។
មនេកាពុំង៉ាជាតិជាម្ដាយ គ្មានទឹកស្ដាយណាយកូនសូន្យម្នាក់ឯង
ពោលក្នុងព្រៃលៃប្រាណប្អូនកន្ទែង ទិព្វចិញ្ចែងលែងក្អឹកនឹកបុត្រភ្ញា ។
ខុសស្នេគកូនខ្ញុំអើម្ដេះទេ កម្មបុព្វវេរផ្ដល់ផលពុំជា
ខ្យល់បក់បោកត្រដាក់ញាក់អង្គា រែងរង៉ាក្ងារខ្លួនកូនយំថ្ងូរ ។
នៅកណ្ដាលឯកឯងចម្បែងលន់ ឃ្លានពេកពន់ទន់ខ្លួនគួរអាសូរ
សែនអាណិតឥតតព៌្វរងអម្បូរ គ្មានថ្ងៃថ្ងូរខ្សត់គ្រប់ក្នុងយប់ទៅ ។
ស្រណោះយំរងឹកក្នុងរាត្រី ផ្អើលបក្សីខ្ចីចុះស្ទុះហើរហៅ
នាំគ្នាស្រក្រសោមទុមព័រក្រៅ ឲ្យកក់ក្ដៅស្ងប់ស្ងាត់បាត់ខ្លោចផ្សា ។
ឯសត្វប្រើសស្មោះសរចរចូលជិត នៅថែបិតនិត្យនែបអែបកន្ធា
ជួយថៃទាំគាំទ្រជូសមាតា ដែលមោហាផាំងបិទឥតរវល់ ។
លុះព្រឹកព្រាងស្វាងព្រះសុរិយា សិស្សព្រះដ្ឋាគយកគន់ក្រោមណ្ឋល
ឃើញបក្សីខ្វលខ្វាយនៅទីងចុល បីដូចកលគុម្ពស្ទាបក្រាបដដាយ ។
ផងទឹកឆ្ងល់សល់សែនចូលទៅជិត ឈ្លោកពិនិត្យយល់ក្មេងស្រស់ពព្រាយ

ក៏បីបមថ្នមថ្នាក់ក័ក្ដ្រីកកាយ រើសយកផ្កាពណ្ណរាយនោះស្ពាយទៅ ។
ក្នុងកញ្ច្រែងផ្លែឈើលើផ្កាផង ស្រស់ទងវែងទិរក័យក្នុងព្រៃជ្រៅ
ប្រើសប្រាសប្រែហែហាមអមពាលពៅ លីលាទៅអឺអឹងទឹងបក្សី ។
សិស្សទាំងឡាយខ្វាយខ្វល់ឲ្យដល់ឆាប់ ទឹងប្រញាប់ប្រាប់នាងគោតមី
ដែលខ្សត់បុត្រផុតពូជព្រួយអស់ក្ដី បានបុត្របវរសមអរលន់ ។
នាំគ្នាប្រៀងសៀងសាយពីឆ្ងាយថា “ឱបុប្ផាថ្វាជ្រះល្អះល្អគន់
ដូចមាសឆ្អិនក្លិនជាប់ស្រទាប់ទន់ សាប់ទ្រលន់ពន់ពេកគួរផ្ដេកផ្ដិត ។
ស្រស់អ៊ូម៉ូះបុប្ផាផ្កាប៉ៃប្រែ រីកបំផ្លែកប្លែកក្រៃថ្ងៃប្រណីត
គួរបីបមថ្នមថ្នាក់ស្នោះស្ន័គ្រចិត្ត ផ្អើលបក្សីតាមស្និទ្ធកិតរហង់ ។
ឱផ្កាល្អស្អាតឆោមឆើតឆាយ គួរបៃងចាត់ថ្វាត់ថ្វាយដោយផ្ចិតផ្ចង់
ដល់គ្រូយើងដាក់កុដិស្រស់បញ្ចង់ កំសាន្តអង្គគ្រាន់ស្បើយល្ហើយចិន្ដា” ។
ពួកបក្សីស្រុះស្រែប្រែគំភ្លេង លាន់គគ្រេងតាមខ្យល់ដល់សាលា
កាមទេពឮហើយកើតសង្កា ស្ទុះច្ឆេច្ឆាចេញទៅមើលនាយអាយ ។
បានដំណឹងដឹងសព្វគ្រប់ប្រការ ស្ងើចអស្ចារ្យទឹងផ្កាថ្វាស្រស់ស្រាយ
ទឹកថាអេះនេះបុណ្យពីព្រេងនាយ មានសំណាយបានកូនសោះសូន្យស្ងាត់ ។
បុត្រក៏ល្អអន់គ្យក័ក្ដូវផង់ បីដូចប្រន្ទុត្របង់ត្របះក្ដាត់
ស្រស់ឧត្ដមសមសក្ដិហាក់បុត្រក្រ័ត្រែ អស់មនុស្សសត្វយល់ហើយមិន
ស្បើយរ័ក្ស ។

ទើបឥសីបុត្រវិសុទ្ធស្អាត ដំរង់បាទវិលថ្កានបានសំណាក់
ស្រែកហៅហៅគោតមីស្រីវរលក្ខណ៍ ឲ្យពក់ទាក់ស្ត្រីជួមកែវធីតា ។
ឯកវិយ៉ាឃើញបុប្ផកូនមក ក៏លៃលកយកពីដៃកស្តា
ស្ទាបអង្អែលថើបថៃដោយស្នេហា ពេញចិន្តាបោសបបក់ប្រាណ ។
សិស្សម៉ីរត្រៀមរៀបចំទឹកខ្ទែង ខ្វល់ចាត់ចែងដំណេកផ្តេកកល្យាណ
នៅរក្សាជុំជិតឥតស្រាកស្រាន្ត លុះដល់បានធាត់ធំចេះចរចា ។
គោតមីបីពពេញហឫទ័យ ហាក់ដូចបុត្រពីផ្ទៃនៃអាត្មា
ឯឥសីឲ្យឈ្មោះបុត្រថា សកុន្តលាផ្កាព្រៃលៃឲ្យសម ។
តាំងពីបានពន្ទុកមកកាលណា កុដិសាលាដែលធ្លាប់ស្ងាត់ជ្រងំ
បែរផ្កាកន្ទ្រាយផ្សាយក្លិនលេងប្រគំ ពេញអាស្រមផ្សំច្រៀងរៀងរាល់ថ្ងៃ ។
ទោះកើតទុក្ខមុខហ្មងយ៉ាងណា តែបានយល់សកុន្តលាកែវថ្លាថ្លៃ
ក៏រកាយត្រេកអរកេចវៃណា ពោលប្រស័យស្រស់ស្រាយសប្បាយចិត្ត ។
លុះបានធំចេះដើរនានចេញក្រៅ ពេលថ្ងៃក្តៅជ្រកម្លប់ឈប់ផ្តេកផ្ចិត
នឹងសត្វព្រៃសប្រលែងប្រលូកស្និទ្ធ ឆាប់វិលថ្កានបានបង់ឥតកពង់ ។
ជាំងសំដីស្តីស្តាប់សព្វពីរោះ សូរសៀងនោះគំហ្ញូតត្រូវកិសរង់
មូលមេត្រីបីបមថ្នមគោមយង់ លំអទ្រង់ធេតធាយកាយទន់ភ្លន់ ។
នាងធំរូបធំកង់ចំរើនវ័យ ស្រស់ប្រពៃសមគួរគួរគយគន់
ស្រស់នេត្រនិលស្រិលស្រួចថ្ងាដោរជន់ ដូចមានមន្តគន់ហើយមិន
ស្បើយនឹក ។

ឯវង់មុខទ្រយុកមូលក្រឡង់ សាច់ម៉ដ្ឋផង់ឈាមថ្វាល្អពន្ទឹក
មាត់ញញឹមប្រិមប្រិយគប្បីទឹក មរៃមញឹកមិនក្ងេចគេចមិនបាត់ ។
សមប្រជ្រុយថ្ពាល់ស្ពាំចាំងាក់ស្នេហ៍ ចាំឲ្យតែស្រឡាញ់មិនអាចកាត់
ដើរយាងយាសល្វាសល្វន់ទន់ពេកក្តាត់ គ្មានវិប័ត្តិត្រង់ណាក្នុងប្រហើរ ។
គាតសើយល់បុត្រពេញដំទង់ កបនោមទ្រង់ទុកយូរពុំប្រសើរ
ក៏ខ្វីឃ្លាតរៀបចំធ្វើដំណើរ ទឹងចេញដើរកប្តីឲ្យស្រីសួន ។
ធីតាស្រស់កំសត់អត់មាតា បានឥសីរក្សាថៃនមនួន
មើលថ្នមថ្នាក់ហាក់ដូចជាកូនខ្លួន គិតថែចូនយប់ព្រឹកទឹកតែថ្ងៃ ។
នាងកំព្រាបានសិស្សរៀនកលប្រាណ រះរាប់គានបីដូចប្អូនវិស័យ
ឯលតាបុប្ផាក្នុងព្រឹក្សព្រៃ បានលកលៃភប់នាងទុកដូចផ្កា ។
នាងមូលមិត្រស្និទ្ធទឹងនាងមាលី ព្រមសូរភីជាប់ជាគូស្នេហា
ទឹងកូនប្រើសតូចមួយខិលក្ងៀវក្ងា តាមកល្យាណត្រឹកសព្វទិសទី ។
នាងទាំងបីវិតខំធ្វើការងារ មើលកស្កុតារដាំស្វរលៅរី
ទទួលក្ងៀវផងទឹកស្រោចផ្កាកុ៎ សំអាតទីបោចស្មៅឲ្យហ្មត់ហ្មង ។
នាងទាំងពីរជាមិត្តសក្តិលា តែកាលណាស្រោចម្ទិះមាត់របង
ដែលនាងដាំចាំថៃតែសព្វផង នាងតែងផ្សង់សូមពរអស់ទេវ្តា ។
សូមអស់ទេពមានបុទ្ធិគិតឲ្យទាន បើដើមម្ទិះនេះមានផ្កាកាលណា
នោះសូមឲ្យស្វាមីសក្តិលា បវរជាចូលមកយកប្អូនស្រី ។

ឱម្លិះអើយប្រញាប់ធាប់ផ្កាឡើង ឲ្យប្អូនយើងក្រមក្សាន្តបានស្វាមី
សុខឥតឃ្មើសលើសគេក្នុងលោកិយ អ្នកមេត្រីខ្ញុំឃ្លាតផ្កាឲ្យធាប់" ។

នាងតាំងបីតែងលុករុកកាន់ព្រៃ គន់រំពៃបុប្ផាផ្កាចំណាប់
កាត់ពីនេះទៅនោះវិលត្រឡប់ សងសារសព្វអាប់អឹងដូចកមរ ។

ប្អូនហែលទឹកត្រឹកត្រែងលេងទៀតវា ហាក់មច្ឆាចង់វង់ស្រស់បវរ
តាំងបោកបាចសាចទឹកអឹកខ្វរ បីដូចទេពអប្សរល្អប្រពៃ ។

លុះព្រលប់ឈប់លេងកាន់ដៃគ្នា វិលត្រឹហាល្ហាសល្ងន់ទន់ល្វតល្វៃ
គន់ដូចកលទេព្ដារក្សាព្រៃ លឿនលយលេចឃ្មៅឃ្មុកង៉ង៉ឹក ៖

មានថ្ងៃមួយធ្លាក់ខ្យល់ខ្វល់ពីត្បូង លើម្លិះប្រចងល្អងលោមប្រលោមស្និទ្ធ
ម្លិះក៏ផ្កាក្ទុនល្អត្រអប់ចិត្ត ជាប់កៀកកិតជិតជាមតាមទៅឆ្ងាយ ។

ឯមាលីស្បូរក៏ពីរន្ទួនល្អង សមដូចប៉ង់ឥតស្រាកសើចក្អាកក្អាយ
លៃផ្សេងផ្សំសំណាងយ៉ាងសប្បាយ ពាំកែក្រាយស្រែកច្រៀងបន្ទរថា ។

' ឱះឱម្លិះនេះផ្កាជំបូងពិត សុភនិមិត្តជិតបានក្សាន្តចិន្តា
បានចួបជិតនិត្យនៃបអែបសយទា សកុន្តលាកល្យាណនឹងបានប្ដី ។

មានបុត្រក្សត្របវរបរចមក ទទួលយកពាលពៅទៅបុរី
អភិសេកជាឯកអគ្គមហេសី កបសិរីសួស្ដីល្បាញល្បីអឺយ" ។ ,

៣

# បរបាញ់សត្វ

អាស្រមឥសីនៅក្នុងដែន    ភពផែនទុស្សន្តថ្កើងអំណាច
សត្រូវស្ងប់ស្ងែងរអែងខ្លាច    ឥតបីអង់អាចហ៊ានទទឹង ។
មានស្ដេចកប់រយជាចំណុះ    ស្រួលស្រុះចុះចូលសូមទីពឹង
ពួកពលកប់លានចិត្តចំប្រឹង    រំពៃសំឡឹងថៃរក្សា ។
ក្នុងក្រោលពេញដោយសេះដំរី    ក្នុងឃ្លាំងរស្មីនៃរថា
សុទ្ធប្រាក់សុទ្ធមាសឧភាសថ្លា    បែងចាំងទេត្រាគួរកោតក្រែង ។
ប្រាសាទប្រសើរល្អស្អាត    សម្បូណ៌បរិវារគាល់គម្ដែង
មានបម៉មបន្ទាយកាយខ្វាត់ខ្វែង    ស្ដេចស្ដែងកបបុណ្យឫទ្ធិល្បាញល្បី ។
មទ័យមហាតលិកបំរើបាទ    ឆ្មៀវឆ្លាតក្អេងក្អាងខាងសំដី
ព្រះអគ្គអាណិតព្រោសប្រណី    ជាមិត្រមេត្រីឥតឃ្លាតឆ្ងាយ ។
ថ្ងៃដែលម៉ឺះផ្កាឯអាស្រម    ទុស្សន្តឧត្តមទ្រង់នឿយណាយ
អផ្សុកស្អុះស្អាប់ពុំសប្បាយ    ក្រហល់ក្រហាយចង់លេងព្រៃ ។
ស្រែកហៅមហាតលិកបញ្ជាថា    "រៀបចំសេនាក្លាមមទ័យ
នាំអញបាញ់សត្វថ្ងៃនេះនៃ    ឆាប់ឲ្យទាន់ពីព្រឹកព្រាង" ។
មទ័យឮពាក្យបរបាញ់ហើយ    ញាប់ញ័រពុំស្បើយគួរសពាង្គ
ព្រោះខ្លួនដុះពោះកំប៉ោងកាង    ចូលបិត្តអកនាងបពាក់នំ ។
ក្នុងព្រៃអាសត្វសាហាវ    បំប្រាវខាំស៊ីស្មើរចង់យំ

តែខ្លាចអំណាចក្សត្រជាធំ ទើបខំចាត់ការទាំងហ្មឺនហ្លួង ៗ
សេនាប្រមូលសេះដំរី នាំគ្នាឃ្លាតខ្លីកេណ្ឌពួកកង
ប្រដាប់ធ្នូស្នាគ្រឿងចាប់ចង ដាវផ្គាក់ដំបងច្បូកគោមរ ៗ
តែមួយរំពេចក៏ហើយស្រេច យាងស្ដេចគង់រថបើកបត់បរ
ក្បួនហែគគ្រេងគ្រេងខ្លាយខ្លរ រឿងឫទ្ធិបវរបររឿងឫទ្ធិ ៗ
ដំរីមួយគូគ្រឿងពិញ្ចាប អមរថក្លឹស្វាបអង់អាចពិត
មានអ្នកកាន់ក្ងស់ដំរីវិចិត្រ អែបស្និទ្ធបាំងថ្វាយព្រះខត្តិយា ៗ
ចំណែកកមទ័យក័យមុខស្ដេះ ទំលើខ្នងសេះក្រោយសេនា
សេះសោតខ្ញុកខ្មាំងយ៉ាប់អាត្មា ខំគន់ព្រឹក្សាការពារខ្លួន ៗ
លុះដល់ទៅព្រៃលៃគ្នាព័ទ្ធ ឮស្សូរសព្ទមាត់លាន់ឮផ្ទួន
ខ្លះភ័យសំណាញ់ជិតមាំមួន ខ្លះផ្ទុំស្នេងក្បួនអស់សត្វផង ៗ
បក្សីកំពុងសុខប្រសើរ វិលវង់ហិចហើរស្វាបតគគ្គង
ដូចស្ទឹកលាស់ថ្មីទន់ទងវង យាសយំរំពងក្នុងព្រឹក្សា ៗ
ខ្លះទំទឹមគ្នារួមមេត្រី បញ្ចុកចំណីកូនស្នេហា
ខ្លះនាំកូនហើរដំរុំគ្នា រញៀររខៀវខ្ញាតតឯក្ទឹក ៗ
ស្រាប់តែពើបពះប្រទះព្រាន ភិតភ័យស្រែកសារ៉ានមមាញឹក
ហើរត្រឡប់តំបន់ស្ទួនសន្ធឹក ផុតទឹកសម្បុកព្រាត់ប្រាសឆ្ងាយ ៗ
មហិង្សាកំពុងនៅលកក់ ដឹងហេតុលាមករបោលប្រញាយ

ដំរីស្រូបទឹកព្រួសខ្ទរខ្ទាយ ស្រោចស្រប់ផោកកាយដំរះប្រាណ ៗ
បុះទឹកបណ្ដែតបណ្ដោយកាង ដូចគល់ចង្ក្រាងដោយស្ទោះស្ទាន
ខ្ទះបក់ត្រចៀកល្ហើយក្បេមក្បាន្ត ឥតគ្មានរំខានពីរឿងអ្វី ៗ
យល់ព្រានមកជិតកិតភ័យក្រៃ ប្រាសបោលប្រៀវប្រែលឿនឥតបី
ប្រមោយកងឡើងលើសិរសី ផាន់ឈើវែងខ្ទីបំពានទៅ ៗ
ពារឈូកក្នុងស្រះរះខ្ទេចខ្ទី វក់វីលកលៃចូលព្រៃជ្រៅ
ផ្អើលក្ដាន់រមាំងចោលលំនៅ រដោររដៅជ្រួលច្របល់ ៗ
ស្ដេចចាប់បរបាញ់សត្វទីទៃ ញាប់ញ័រខ្ញុរព្រៃភ័យខ្វក់ខ្វល់
អស់ម្រឹគថ្ពូចថ្ពូរស្ទូរបល់ ត្រូវសរផាច់ខ្យល់ដល់ដីស្លាប់ ៗ
ខ្លាធំខ្លាតូចស្រែកបម្រៃង ស្លាប់ស្បែងផ្សំស្ទូរត្រែអឹងអាប់
សត្វផងត្រូវព្រួញដួលផ្ទារផ្កាប់ ខ្លះត្រូវគេកាប់ស្លាប់ប្រផាង ៗ
ខ្លះផាប់អន្ទាក់ពាក់សំណាញ់ ខ្លះរត់សស្រាញ់ហត់ដួលផាង
រងំយំថ្ងូរស្ទូរច្រើនយ៉ាង តេងតាងផ្ទួនផ្ទារត់ទៅមក ៗ
សត្វខ្លាឆ្ការត់ខ្វល់ពេញព្រៃ ក្រពើលលៃវៃមុជជ្រក
បក្សីព្រោងព្រាតដូចពពក ពួនមកងងឹតហាក់ជិតព្យុះ ៗ
ព្រានប្រឹងសត្វប្រែកែដោះដៃ ព្រានខំកែខៃហាក់ស្ទុស្ទុះ
ស្ទាក់មុខស្ទាក់ក្រោយចាក់មុតធ្ងុះ សត្វលុះក្ដីមរណ៍គរលើគ្នា ៗ
ស្រណោះស្រណោកសោកអាល័យ សង្រេងសង្រៃព្រាត់កព្រា

ស្តាយដ៏ពស្តាយជន្មឥតគណនា
បែកគ្នីបែកគ្នានាគ្រាហ្នឹង ។
អានាថអាណិតអ្វីម្ល៉េះទេ
រិះគិតរូបគេវេជញ្ជឹង
ជីវិនជីវិតឥតទីពឹង
ពំនាក់ពំនឹងវឹងបម្បែង ។
ពជាឯកអង្គគង់ពជរថ
បែរបត់ដេញប្រើសព្រះអង្គឯង
ប្រើសស្ទុតបោលស្ទុងប្រឹងខ្វាត់ខ្វែង
រហ័សរហែងបីដូចខ្យល់ ។
ដូចផ្លេកបន្ទោររត់លឿនស្ទៅ
សំដៅចាប់ប្រើសតាមកិច្ចកល
ដាប់ពួកសេនាអស់គ្មានសល់
ហេតុផលពីព្រេងនាំក្សត្រក្សាន្ត ។
រថហើយនឹងប្រើសប្រៃដែងគ្នា
ស្ទុះស្ទាលោលោតឥតឈប់ខាន
ដេញគ្នាប្រជិតកិតតាមដាន
ប្អូនបានយល់គ្នាប្អូនឃ្លាឃ្លាត ។
ឆ្ងាយទៅឆ្ងាយទៅគាត់ព្រឹក្សា
រត់តាមប្រើសឆ្ងាឥតរវាត
កាត់ស្រែបម្ការក្វាគគាត
ននះននាតដល់អាស្រម ។
ទីនោះស្ងប់ស្ងាត់ខ្ជាត់ភ័យកិត
ឥតព្រានហ៊ានជិតប៉ូលបង្ខំ
ជាឋានឥសីលោកបង្ក្រម
មិនឲ្យប្រឡំទីដទៃ ។
ការបរបាញ់សត្វត្រូវហាមឃាត់
សត្វផងគ្មានក្លាតព្រាត់ទីទៃ
ពេលដែលកំពុងផ្លួលក្ងៃព្រៃ
ទីនោះនិរភ័យស្ងប់ធម្មតា ។
សត្វសេកស្វាបទៀវអេរស្រួលស្រុះ
បំពុះក្រហាមបឹកផលា
ចំណែកកង្កងស្ទឹងទឹកទឹងថ្លា
ហង្សស្រសស្ហាលឿនលយលេង ។
ពួកប្រើសនទៀលលើស្មៅខ្ចី
ក្ងគុម្ពលាស់ថ្មីលាន់គគ្រេង

ឯសកុន្តលាកំពុងគេង ខ្សឹបលេងនឹងមិត្តទាំងពីរប្រាណ ៗ
ស្រាប់ប្រើសកំសត់ហត់បូលមក រត់ជ្រកក្រោមជើងកែវកល្យាណ
ទឹកភ្នែកសស្រាក់ព្រួយរំខាន ប្រាសប្រាណដេកស្ដឹកស្ទើរសន្លប់ ៗ
ធីតាប្រាក់ឥតឃ្លាន់ឃ្លើស អង្អែលកូនប្រើសញ័របំប្រប់
ខឹងនឹងនរណាក្លាចប្រប់ ប្រសប់រកពានទន្ទ្រានទី ៗ
ទើបនាងងើបក្រសចេញទៅក្រៅ យាងយាសចៅពៅត្រាច់ចរលី
ស្រាប់តែពើបពះព្រះភូមី នារីឈរទ្រឹងសំឡឹងត្រង់ ៗ
បីដូចព្រះឥន្ទសួគ៌ទិពស គង់លើរថមាសស្រស់បញ្ចង់
ប្រដាប់អម្ពរល្អអស់អង្គ ព្រះភ័ក្ត្រផូរផង់ប្រឹងផុតភព ៗ
មាឌមាំសមពងរុងរឿងឫទ្ធិ ឧណ្ណាលោមជិតក្រាស់គ្រាន់គ្រប់
ពោលគ្រប់ដណ្ដាប់នេត្រជាម្លប់ សម្ភពប៉ះហើយក្លួបស្នេហា ៗ
នេត្រសោតក្ដីផ្ទេកក្រឡេកដាក់ ដូចហាក់លំពែងមុតចិន្ដា
ព្រះឧស្ឋប៉ប្រឹមសមសក្ដា នាសាស្រួលស្រួចស្រស់បំណាន ៗ
នាងនាដភ្លាំងភ្លេចគំនិតដើម ដង្ហើមញ័រញាប់បំប្រប់ប្រាណ
មានអ្វីថ្មីដល់ខ្វល់រំខាន កល្យាណឈរទ្រឹងរឹងអង្គា ៗ
ទុស្សន្តក្រឡេកយល់នារី ន័យន៍នេត្រទាំងទ្វីប្រសព្វគ្នា
ពោលជាប់ដេញទៅនៅយូរយារ យូរយារពុំឃ្លាពុំឃ្លាតឡើយ ៗ

(មានត)

## បញ្ញត្រៃ: (មានត)

ប្រពន្ធអ្នកកាត់សក់ ដោយខ្លាចគេស្គាល់សម្លេង មិនហ៊ានឆ្លើយតប ៗ អ្នកតម្បាញសួរហើយសួរថែមទៀតពីរបីដងដដែលៗ ដល់ស្រីនោះមិនឆ្លើយ ក៏ក្រោកមួយរំពេចកន្ត្រាក់យកចបកាប់មុខមុត ទៅចោះបំប្រមុះប៉ុត ដាច់ប្រមុះធ្លាក់ក្តុកដល់ក្តារហូរឈាមសស្រាក់ ទើបពោលថា “នែមេចិត្តចើក! យើមេហន៍ឯងហ៊ានទៅសៀម មិនចង់និយាយនឹងអញផង បានតែកញ្ចុតយ៉ាងនេះបានសមបុកហន៍ឯង” និយាយយ៉ាងនេះរួចហើយក៏ចូលទៅដេកវិញទៅ ៗ

ឯទេវសមិ: បានដឹងមារយាទស្រីនោះទាំងអស់ ណាមួយវិនាសទ្រព្យសម្បត្តិអស់រលីងផង ណាមួយទៀតស្រែកឃ្លានខ្លាំងផង ថែមទាំងអត់ងងុយដេកមិនលក់ផង ក៏កើតខ្ញាញ់ក្នុងចិត្តឥតឧបមា ៗ ប្រពន្ធអ្នកតម្បាញ ទៅជួបទេវទត្តជាសហាយសប្បាយចិត្តត្រេកត្រអាលដោយក្តីស្នេហាស្កប់ស្កល់ហើយត្រឡប់មកកាន់ផ្ទះវិញ ហើយនិយាយទៅកាន់ប្រពន្ធអ្នកកាត់សក់ថា “នែម្នាក់! ឯងស្រួលបួលឬទេ? ម្តេចទៅអាកំណាចចង្រៃនោះវាមិនក្រោកមករករឿងនឹងហន៍ឯងទេឬ ក្រោយដែលអញចេញបាត់ទៅ?” ៗ ប្រពន្ធអ្នកកាត់សក់ឆ្លើយតបថា ‘ម្នាក់អើយ! លើកលែងតែប្រមុះចេញ អវយវៈក្រៅពីនោះនៅស្រួលបួលទេ, មក! មកស្រាយអញឲ្យឆាប់ទៅកុំឲ្យវាឃើញអញទាន់ មុនអញទៅ

ផុះ” ៗ ក្រោយនោះមក, អ្នកតម្បាញក្រោកឡើងទៀត ហើយនិយាយបញ្ចោះថា “ម្តេចមេសំផឹង! ម្តងនេះទៀតមេហាងឯងមិននិយាយឆ្លើយនឹងអញទៀតឬអ្វី? មេហាងឯងចង់ឲ្យអញដាក់ទណ្ឌកម្មឲ្យធ្ងន់ជាងមុនទៅទៀតឬ? ម្តងនេះអញនឹងកាត់ត្រចៀកមេហាងឯងទៀត” ប្រពន្ធក្តៅណាស់ ឆ្លើយដោយសំឡេងត្រគោះបោកបោះថា “យី! យី! អាល្ងង់គម្រក់! អីអាឯងហ៊ានមកប្រមាថមើលងាយចង់កាត់ច្រមុះចង់កាត់ត្រចៀកអញ ដែលជាស្រីមានលក្ខណ៍ហើយស្មោះត្រង់នឹងប្តីផង បើទុកជាស្តេចចតុលោកបាលក៏លោកជ្រាបពីអញដែរ, ព្រោះថា :–

១៨២ – ព្រះអាទិត្យ, ព្រះចន្ទ្រ, ព្រះពាយ, ព្រះអគ្និ, ព្រះទេវ្រស៍, ព្រះភូមិ ទឹក, ហឫទ័យ, ព្រះយមៈ, ថ្ងៃ, យប់, សន្ធ្យាទាំងពីរ នឹងព្រះធម៌ តែងស្គាល់សេចក្តីប្រព្រឹត្តនៃនរជន ៗ

ថាបើអញជាស្ត្រីមានលក្ខណ៍ពិតមែន សូមឲ្យព្រះជាម្ចាស់ទាំងអស់នោះធ្វើឲ្យច្រមុះអញដូចដើមវិញ ថាបើអញមានចិត្តក្បត់ប្តី សូម្បីតែដោយចិត្ត ក៏សូមឲ្យព្រះជាម្ចាស់បំផ្លិចបំផ្លាញរំលាយឲ្យខ្ទេចផង់ដូចជាផែះកុំខាន ៗ កាលនិយាយស្បថស្បែយ៉ាងនេះរួចហើយ ប្រពន្ធនោះក៏និយាយកំញើញញទៅកាន់ប្តីម្តងទៀតថា “នែអាកំណាច អាឯងមកមើល! ដោយតេជានុភាពអញជាស្ត្រីមានលក្ខណ៍ច្រមុះអញដុះលូតលាស់ប្រាកដដូចដើមវិញហើយ” ៗ ឯអ្នកតម្បាញ កាលឮសូរប្រពន្ធពោលអួតអាង

ដូច្នោះអត់ទ្រាំមិនបានក៏ផុតបន្ទុះចេញមកមើល ឃើញប្រមុះនៅដូចដើម ឃើញឈាមក្រហមច្រាលនៅលើក្តារ ក៏តក់ស្លុតរន្ធត់ចិត្តយ៉ាងខ្លាំង ហើយស្រាយប្រពន្ធចេញពីចំណងក្លាម លើកទៅដាក់នៅលើគ្រែ និយាយសសោះអន្ទងលួងលោមប្រលោមដោយកាមផ្សេងៗ ។

ទេវសម៌ៈ បានឃើញប្រព្រឹត្តការនោះទាំងអស់ កើតតប់ប្រមល់ខ្វល់ចិត្តក៏ពោលថា :-

១៨៣ - អសុរឈ្មោះសម្ពរ ឈ្មោះនមុចិ ឈ្មោះពលិ ឈ្មោះកុម្ភីនសា ទាំងអស់នេះ ចេះមាយាដ៏ប្រសើរ តែស្ត្រីភាព ចេះមាយាប្រសើរជាងអសុរទាំងអស់នោះទៀត ។

១៨៤ - ស្ត្រីភាព បើគេញញឹម ញញឹមតមកវិញ បើគេយំ ធ្វើជាយំតបវិញ បើគេមិនស្រឡាញ់ខ្លួន ធ្វើឲ្យគេស្រឡាញ់ដោយសំដីគួរជាទីស្រឡាញ់គ្រប់កាលទាំងពួង ។

១៨៥ - តាបសឈ្មោះឧសនា នឹងព្រះព្រឹហស្បតិ ចេះមាយាសាស្ត្រតែមិនប្រសើរជាងប្រាជ្ញានៃស្ត្រីភាពទាំងឡាយទេ ព្រោះហេតុនោះ នរជនធ្វើដូចម្តេចនឹងទប់ទល់ចំពោះស្ត្រីភាពទាំងឡាយបាន ?

១៨៦ - ស្ត្រីភាពតែងនិយាយពាក្យមិនពិតទៅជាពាក្យពិត ពាក្យពិតទៅជាពាក្យមិនពិតវិញ បើដូច្នេះ តើក្នុងលោកនេះ បុរសណាជាអ្នកប្រាជ្ញអាចរក្សាខ្លួនបានចំពោះស្ត្រីភាពទាំងឡាយ ?

១៨៧ – មិនគួរធ្វើចិត្តឲ្យជាប់ខ្ជាំងចំពោះស្ត្រីភាពទាំងឡាយទេ ព្រោះជាអានុភាពស្រី បើគេបណ្ដោយឲ្យចំរើន នឹងរឹតតែមានកម្លាំងខ្លាំងឡើងណាស់ ស្ត្រីភាពទាំងឡាយលេងនឹងប្រុសទាំងឡាយ ដែលមានចិត្តជាប់ស្អិតចំពោះខ្លួនដូចជាគេលេងក្អែកកំបុតស្លាបដូច្នោះ ។

១៨៨ – ស្ត្រីភាពនិយាយពីរោះគួរជាប់ចិត្ត ដោយទឹកមុខញញឹមស្រស់ ប្រហារដោយចិត្តដ៏មុះមុត សំដីផ្អែមដូចទឹកឃ្មុំ តែក្នុងចិត្តពេញពោរដោយពិសក្ដៅក្រៃលកលដ៏ខ្លាំង ។

១៨៩ – ព្រោះហេតុនោះបានជា បុរសទាំងឡាយ កាលដែលស្រវឹងដោយកិលេសគឺកាមសុខ ផ្ញាក់មាត់ យកក្ដាប់ដៃវាយហឫទ័យគឺប្រចាច់សុដននៃស្ត្រី ដូចជាឃ្មុំដែលស្រវឹងទឹកឃ្មុំ ក្រេបផ្កាឈូកដូច្នោះ ។

១៩០ – គុណសម្បត្តិស្ត្រីដែលមានក្អែកល្អដូចក្អែកម្រឹគ ដែលបុគ្គលមើលឃើញ សុទ្ធតែជាគំនរទោសទាំងអស់ គឺ សុដនក្បាំ ក្អែកក្រឡេកក្រឡាប់ ញាក់មុខ កិរិយាសាយក្លិនសក់ ពោលពាក្យអៀនអន់ត្រកៀកសាយ ចិត្តញញើតញញើម និយាយត្រប់តាលទាំងពួង ធ្វើមាយាជាមួយសហាយ បើដូច្នោះតើ ស្ត្រីទាំងឡាយមុខនឹងជាទីស្រឡាញ់នៃបុរសទាំងឡាយកើត? ។

១៩១ – ក្នុងលោកនេះ លោកណាហ្ន៎ បង្កើតយន្តគឺស្ត្រីទុកដូចជាសៀវនៃសេចក្ដីសង្ស័យ ដូចជាកពាតតវិន័យ ដូចជានគរនៃ

ទណ្ឌកម្ម ដូចជាការនិប្រកមាយាគ្រប់ប្រការ នរជនជាទេសកដ៏ប្រសើរ ផាន់ខ្ពស់ចូលទៅកាន់យកមិនបាន ជាពិសពុលលាយដោយទឹកអម្រឹត សម្រាប់បំផ្លាញធម៌ ។

១៩២ – ស្ត្រីភាពសើចជាមួយ យំជាមួយ ដូចជាហេតុការជារបស់ខ្លួន ជួនកាល ធ្វើឲ្យគេទុកចិត្ត ជួនកាល មិនធ្វើឲ្យគេទុកចិត្ត ព្រោះហេតុនេះ នរជនដែលមានត្រកូលនឹងមានសីលធម៌ គួរគប្បីចៀសចេញពីស្រី ឲ្យដូចជាបំពង់ទឹក[១] ដែលគេចងព្យួរទុកក្នុងព្រៃស្មសាន ។

១៩៣ – មុនដំបូង ស្រីភាពធ្វើឲ្យស្រឡាញ់ បើមិនទាន់ដឹងថាប្រុសជាប់ចិត្តចំពោះខ្លួនដរាបណាទេ នៅតែធ្វើឲ្យស្រឡាញ់ដរាបនោះ លុះត្រាតែដឹងថា ប្រុសជាប់ក្នុងអន្ទាក់កាមទេពខ្លួនហើយ ស្រីភាពនឹងស្រាវទាញដូចជាព្រានប្រមង់ចាប់ទាញត្រីដែលជាប់ដោយទុយសន្ទូច ។

១៩៤ – ស្ត្រីមានសភាពមិនទឹងធឹង ដូចជារលកនៃសមុទ្រ មានភគៈតែមួយរំពេច ដូចជាស្នាមនៃពពកក្នុងពេលសន្ធិយារាត្រី កាលបើសេចក្ដីប្រាថ្នារបស់ខ្លួនបានសម្រេចហើយ តែងលះបង់ចោលបុរសដែលខ្លួនមិនត្រូវការត្រាមដូចជាគេចោលកាកល័ក្ត ដែលគេច្របាច់រួចហើយ ។

---

១ ទំនៀមប្រទេសឥណ្ឌា គេចងបំពង់ទឹកទុកចោលក្នុងព្រៃស្មសាន ទឹកនេះគេមិនទៅផឹកទេ ។

១៩៥ – ពោលពាក្យមិនពិត កាចសាហាវ មាយា លង់ខ្លៅ លោភលន់ក្រៃពេក ស្មោកគ្រោក ឥតបិត្តអាណិត ទាំងនេះជាទោសនៃស្រីភាពកើតអំពីកំណើត ។

១៩៦ –[1] សេចក្ដីពិត ស្រីភាព មានពិសពុលនៅខាងក្នុង មានពណ៌គួរជាទីពេញចិត្តនៅខាងក្រៅ ឧបមាដូចផ្លែកុញ្ញា[2] (ផ្លែស្លង?) ។

កាលដែលបណ្ដាយចិត្តឲ្យវិតក្កត្រិះរិះតែពីរឿងនេះ បរិញ្ញាជកទេវសម៌ះសោចសេលយ៉ាងខ្លាំង ដេកមិនលក់បកមិនល្ហើយរហូតរាល់ព្រឹក ។ ឯនាងមេអណ្ដើកករិយាអ្នកកាត់សក់ កញ្ចុតប្រមុះកំបុតថ្ពាល់ ដើរត្រឡប់ទៅផ្ទះវិញ ទៅដល់ហើយគិតថា "អាត្មាអញគិតធ្វើដូចម្ដេចអេះ ឥឡូវនេះ? គិតធ្វើដូចម្ដេចឲ្យប្រមុះរាជាសះដូចដើមវិញ?" ។ កាលដែលនាងនោះគិតរកឧបាយដូច្នេះ អ្នកកាត់សក់ជាប្ដីនាងនៅឯព្រះបរមរាជវាំងនៅ

---

១— បញ្ញតន្ត្រច្បាប់នៃលោកប្រាសាទសាស្ត្រ ផ្សាយដោយភតិរបុស្តកាល័យ ពារាណសី មានគាថាលើសផ្លូវច្នេះ ក— ស្ដេចម្រឹគ (សីហៈ) មានកេសរសំពោង មានបង្កួមស្មើមគួរខ្លាចក្ដី នាគ (ដំរី) ចុះប្រេងមានប្រេងហូរហៀរ, គុម្ពត្របៀករលោងស្រិលក្ដី អ្នកប្រាជ្ញក្ដី បុរសក្លៀវក្លាក្នុងសមរភូមិក្ដី កាលបើចូលទៅជិតស្រីហើយត្រឡប់ទៅជាបុរសគម្រក់ក្រៃលែងទៅវិញ ។ ១— ស្រីភាព ធ្វើកលមាយាបែបផ្សេងៗ ធ្វើឲ្យស្រវឹងកាម ញញឹមម៉ឺតប្រាយ កំញើញដោយកាម ធ្វើឲ្យត្រេកអរដោយកាម ធ្វើឲ្យជាប់ចិត្តក្នុងកាម កាលបើចូលទៅដល់ចិត្តទន់នៃបុរសហើយ ស្រីដែលមានភ្នែកល្អនឹងមិនធ្វើឲ្យបុរសផុងខ្លួនឬអ្វី? ។ ២— ផ្លែដើមឈើតូចៗ មានពណ៌ក្រហមក្រមៅ ល្អមើលពីខាងក្រៅ តែសាច់ខាងក្នុងសុទ្ធតែពិសពុល ។

ឡើយ ព្រឹកព្រានឡើង ទើបគាត់មកផ្ទះ លុះមកដល់មាត់ទ្វារផ្ទះ ប្រញាប់ដោយមានកិច្ចការច្រើនពេក គាត់ស្រែកទៅប្រាប់ប្រពន្ធថា: “នាងអើយ ! យកស្រោមកាំបិតហុចគ្នាបន្តិចអញប្រញាប់ទៅធ្វើការ” ។ មេស្រីចិត្តសាមាន្យ ដោយខ្លួនកញ្ចុតច្រមុះនៅតែក្នុងផ្ទះ មិនហ៊ានចេញមកក្រៅ ហើយថែមទាំងរកឧបាយឃើញសមតាមបំណងខ្លួនផង ក៏ដកកាំបិតតែមួយចេញពីស្រោមហើយបោះប្រួសទៅដីឲ្យប្ដី អ្នកគាត់សក់ឃើញប្រពន្ធបោះកាំបិតតែមួយមកឲ្យ ក្នាញ់ណាស់ក្រោធឆេវឆេះដូចភ្លើងក៏បោះកាំបិតទៅឲ្យភរិយាវិញ ។ ឯមេកាលកណ្ណី ឃើញមានឱកាសត្រូវទំនងត្រង់ពេលកាំបិតបោះទៅវិញទៅមកដូច្នេះ ក៏លើកដៃផ្គងឡើងលើ ស្រែកអាក្រោសយំយែកពេញទ្រពងមាត់រត់ចេញពីផ្ទះថា: “ឱលោកអើយ ! មើលចុះ អាចោរកំណាចនេះវាកាត់ច្រមុះខ្ញុំដាច់ទៅហើយ មិនគួរសោះ ខ្ញុំជាស្រីគ្រប់លក្ខណ៍ជួយខ្ញុំផងៗ ! ។ ពេលនោះពួកបុរសរត់មកដល់ បបួលគ្នាព្រួតវាយអ្នកគាត់សក់ទាល់តែទ្រម ចងដាក់ច្បាកយ៉ាងមាំ ហើយនាំទៅកាន់សាលាវិនិច្ឆ័យ នាំយកទាំងភរិយាកញ្ចុតច្រមុះទៅផង ទៅដល់ហើយប្ដឹងចៅក្រមថា: “សូមលោកអញ្ជើញស្ដាប់ចុះ អ្នកគាត់សក់កំណាចនេះហ៊ានកាត់ច្រមុះប្រពន្ធខ្លួនដែលជាស្រីកែវឲ្យដាច់កំបុតថ្ងយ ស្ត្រីនេះឥតទោសកំហុសអ្វីសោះ សូមលោកចៅក្រមកាត់ទោសទៅតាមអំពើអាក្រក់របស់វាឲ្យទាន” ។ ចៅក្រម កាលបាន

ស្ដាប់ហើយ សួរទៅថា: "នែអ្នកកាត់សក់! ហេតុអ្វីក៏ឯងហ៊ានកាត់ច្រមុះប្រពន្ធឯងដូច្នេះ? វាផិតឯងឬ? ឬមួយវាប្រុងសម្លាប់ឯង? ឬពុំនោះទេ វាលួចទ្រព្យអ្វីឯង? ចូរឯងនិយាយប្រាប់ទោសវាមក?" ។ ពេលនោះ អ្នកកាត់សក់ទ្រមក្រំខ្លួនដោយត្រូវព្រនង់ខ្ទាំងពេក រកនិយាយមិនកើត ។ កាលនោះ ចៅក្រមឃើញអ្នកកាត់សក់មិនឆ្លើយ ក៏សំគាល់ថាខុសពិតមែនទើបនិយាយតទៅថា. "បើដូច្នោះ ពាក្យដែលរាជបុរសគេនិយាយនោះត្រឹមត្រូវហើយ ឃើញកំណាចនេះវាហ៊ានកាត់ច្រមុះប្រពន្ធវាដែលស្លូតត្រង់ ហើយឥតទោសពៃរ៍យ៉ាងនេះហ្ន៎! ព្រោះថា:–

១៩៧– បុរសធ្វើអំពើអាក្រក់ តែងតក់ស្លុតចំពោះកម្មអាក្រក់ខ្លួនឯង គឺប្រែសំឡេងនឹងពណ៌មុខ សំដែងអាការមុខភ័យខ្លាច អស់តេជានុភាព ។

១៩៨– ដើរទ្រេតទ្រោត ទឹកមុខប្រែពណ៌ ហូរញើសជោកថ្ងាស និយាយប៉ប៉េប៉ប៉ុប ។

១៩៩– នរជនធ្វើអំពើអាក្រក់ បើចូលក្នុងសាលាវិនិច្ឆ័យ តែងដាក់មុខសំឡឹងចុះក្រោម ហេតុនោះ អ្នកប្រាជ្ញអាចកំណត់សំគាល់បាននូវនរជនអាក្រក់នោះ ដោយគ្រឿងសំគាល់ទាំងឡាយនេះឯង ។

២០០– នរជនបរិសុទ្ធ មានទឹកមុខថ្លារីករាយ និយាយពាក្យច្បាស់លាស់ សំដែងអាការមុខក្លាហាន បើចូលក្នុងសាលាវិនិច្ឆ័យ និយាយដោយម៉ឺងម៉ាត់នឹងដោយអង់អាច ។

ហេតុដូច្នេះហើយបានជាគេសំគាល់ឃើញលក្ខណៈខ្លួនថាជាមនុស្សមានទោសទុច្ចរិត ទោសដែលវាប្រព្រឹត្តរំលោភរិយាវានេះត្រូវសម្លាប់ ចូរចាប់វាទៅឲ្យឡើងឈើស្ទូលឬអាកាដែកទៅ ។ គ្រានោះ បរិព្វាជកទេវសមិៈ ឃើញពេជ្ឈឃាតនាំអ្នកទោសនោះយកទៅកាន់ទីសម្លាប់ ដើរចូលទៅរកចៅក្រមហើយនិយាយប្រាប់ថា នែលោកចៅក្រម! លោកកាត់ទោសសម្លាប់មិនយុត្តិធម៌ទេ, អ្នកនេះជាអ្នកកាត់សក់ ជាមនុស្ស-សុចរិត សូមលោកចាំស្តាប់ពាក្យអាត្មាអំពាបសិន រឿងនេះដូច្នេះគឺ ចចកស្លាប់ព្រោះបម្រាំងពាតែ ខ្ញុំអន្តរាយព្រោះអាសាឍរកូត នាងមេអណ្តើកកើតទោសព្រោះផនផៃ ទោសទាំង ៣ យ៉ាងនេះ កើតពីខ្លួនឯងធ្វើ ៗ ចៅក្រមទាំងឡាយសួរឡើងថា: ' ចុះរឿងនោះតើដូចម្តេច?" ។ ទេវ-សមិៈក៏រៀបរាប់រឿងទាំង ៣ នាក់នោះជូនចៅក្រមស្តាប់ តាំងពីដើមដល់ចប់ ។ ចៅក្រមបានស្តាប់ហើយ កើតមានសេចក្តីស្ញើចអស្ចារ្យក្នុងចិត្តជាអនេក ក៏បង្គាប់ឲ្យរាជបុរសលែងអ្នកកាត់សក់នោះទៅ ទើបបបួលគ្នានិយាយថា ខុ !

២០១ – ព្រាហ្មណ៍ ១ ក្មេង ១ ស្រី ១ តាបស ១ មនុស្សឈឺ ១ ទាំង ៥ ពួកនេះបុគ្គលមិនគួរកាត់សម្លាប់ទេ ព្រោះការវិកលវិការរាងកាយនៃជនពួកនេះ ទុកជាទោសទុច្ចរិតស្រេចទៅហើយ ។

បើតាមការគួរ ត្រូវតែកាត់ត្រចៀកមេចោរដកទងនេះថែមទៀតទើបសម ព្រោះទោសវាកត្បតច្រមុះតែប៉ុណ្ណោះមិនធួនទេ ។ កាលនិយាយ

រឿងការនេះចប់ស្រេចហើយ ទេវសមិះក៏បាត់ក្តីសោកស្តាយដែលកើតពីការខាតបង់ទ្រព្យសម្បត្តិ ហើយគាត់ត្រឡប់មកវិញចូលទៅកាន់អាស្រមនៅជាសុខសប្បាយដូចដើមវិញ ។ ហេតុនោះហើយបានជាខ្ញុំ (ទមនកៈ) និយាយថា: "ចចកស្លាប់ព្រោះចម្បាំងពពែ" ដូច្នេះជាដើម ។

ករដកៈសួរថែមទៀតថា: "ទេវសមិនេះ ប៉ិនប្រសប់កលឧបាយម៉្លេះ ម្តេចក៏អាសាឍភូតិបោកប្រាស់បានហ្ន៎? ។ ទមនកៈឆ្លើយថា –

២០២ – សូម្បីព្រះព្រហ្មក៏មិនងាយយល់ទីបំផុតនៃការឆបោកដែលបុគ្គលលាក់យ៉ាងស្ងាត់បានដែរ ព្រោះអ្នកតម្បាញ យកភេទជាព្រះវិស្ណុចូលទៅលួចយកព្រះរាជកន្យាបាន ។

ករដកសួរថា: "ចុះរឿងនោះ តើដូចម្តេច?" ។ ទមនក.រៀបរាប់ដូចតទៅនេះថា :–

## កថាទី ៦

## រឿងអ្នកតម្បាញក្លែងភេទជាព្រះវិស្ណុ

អ្នកតម្បាញនឹងជាងរថទាំងពីរនាក់នេះ អាស្រ័យនៅក្នុងតំបន់មួយជាមួយគ្នា ហើយធ្លាប់ជាមិត្តភក្តិនឹងគ្នាតាំងពីកាលនៅជាកុមារ ធ្លាប់លេងល្បែងផ្សេងៗជាមួយគ្នា ។ ថ្ងៃមួយ មហាជនរៀបចំពិធីលេងមហោស្រពបូជាទេវតា នៅអាស្រមបទទេវតាក្នុងតំបន់នោះ ។

(មានត)